«នៅពីក្រោមភាពតានតឹង និងសេចក្ដីព្រួយបារម្ភក្នុងជីវិតសម័យទំនើបនេះ មានសំណួរពីបុរាណកាលមួយដែលលាក់ខ្លួនពួនស្ងួរថា «តើខ្ញុំល្អគ្រប់គ្រាន់ហើយឬក៏នៅ?» និងថា «តើខ្ញុំធ្វើបានច្រើនគ្រប់គ្រាន់ហើយឬក៏នៅ?»។ សំណួរទាំងនេះលងបន្លាចមនុស្សមួយចំនួន ហើយជំរុញមនុស្សមួយចំនួនទៀត និងធ្វើឲ្យមនុស្សជាច្រើននាក់មានការនឿយហត់រហូតទាល់តែលែងខ្វល់ខ្វាយ ឬធ្លាក់ក្នុងសេចក្ដីអស់សង្ឃឹមតែម្ដង។ នៅក្នុងទំព័រទាំងនៃសៀវភៅនេះ–ដែលងាយស្រួលអានផង និងគួរឲ្យទុកចិត្តបានផង–គឺលោក Michael Reeves បានបើកកកាយទាំងឫសគល់នៃបញ្ហារបស់មនុស្សយើង និងទាំងភាពទ័លច្រកនៃចម្លើយផ្ទាល់ខ្លួនរបស់យើងចំពោះបញ្ហានោះ។ ប៉ុន្តែ បន្ទាប់មក ក្នុងរបៀបដ៏សាមញ្ញ និងគួរឲ្យទាក់ទាញចិត្ត គឺគាត់បានបង្ហាញយើងឲ្យឃើញអំពីដំណោះស្រាយផ្លាស់ប្ដូរជីវិត ដែលដំណឹងល្អរបស់គ្រីស្ទបរិស័ទបានផ្ដល់ឲ្យយើង។ សៀវភៅ «ការបានសុចរិតជាមួយនឹងព្រះជាម្ចាស់» (“Right with God”) គឺជាសៀវភៅដ៏ខ្លីមួយ ប៉ុន្តែមានសារដ៏មានតម្លៃរហូតអស់កល្បជានិច្ច»។

**Sinclair B. Ferguson**

Chancellor’s Professor of Systematic Theology,
Reformed Theological Seminary;

Teaching Fellow, Ligonier Ministries

«កូនសោតូចមួយអាចបើកទ្វារដ៏ធំសម្បើមដែលនាំទៅរកសេរីភាពបាន។ សៀវភៅនិក្ខេបបទដ៏ខ្លីមួយនេះរបស់លោកបណ្ឌិត Reeves ដែលជាអ្នកនិពន្ធដ៏មានសមត្ថភាពខ្ពស់ម្នាក់ បានក្ដោបក្ដាប់នូវកូនសោនៃសេចក្ដីសន្យារបស់ព្រះជាម្ចាស់ ក្នុងការរាប់មនុស្សមានបាបថាជាមនុស្សសុចរិត ដោយឥតគិតថ្លៃ តាមរយៈជំនឿលើព្រះគ្រីស្ទតែមួយព្រះអង្គគត់។ សូមព្រះជាម្ចាស់ប្រើប្រាស់សៀវភៅនេះ ដើម្បីនាំមនុស្សជាច្រើននាក់ឲ្យទទួលបានសេរីភាពខាងឯវិញ្ញាណ។

សូមទិញសៀវភៅដែលងាយស្រួលអាននេះ ដែលខ្ញុំចង់ណែនាំយ៉ាងខ្លាំងទុកជាច្រើនក្បាល ដើម្បីចែករំលែកបន្តទៅកាន់អស់អ្នកដែលមិនទាន់ទទួលបានសេចក្តីសង្គ្រោះ និងចែករំលែកទៅកាន់អ្នកដែលបានសង្គ្រោះហើយប៉ុន្តែកំពុងតស៊ូស្វែងរកសេចក្តីរឹងមាំខាងឯជំនឿ ហើយក៏សូមចែករំលែកទៅកាន់អស់អ្នកជឿដែលមានជំនឿរឹងមាំស្រាប់ហើយ ដើម្បីជួយពង្រឹងជំនឿជាក់លាក់របស់ពួកគេឲ្យកាន់តែមាំមួនបន្ថែមទៀតចុះ»។

**Joel R. Beeke**

President, Puritan Reformed Theological Seminary,

Grand Rapids, Michigan

«ប្រហែលជាគ្មានសំណួរណាដែលមនុស្សណាម្នាក់អាចសួរដែលមានសារៈសំខាន់ជាងសំណួរដែលថា “តើខ្ញុំទទួលបានការរាប់ជាសុចរិតជាមួយនឹងព្រះជាម្ចាស់ហើយឬនៅ?” នោះឡើយ។ សៀវភៅដ៏មានប្រយោជន៍មួយនេះបានពិនិត្យស្រាវជ្រាវអំពីរបៀបដែលព្រះជាម្ចាស់ផ្ទាល់ឆ្លើយតបនឹងសំណួរដ៏សំខាន់ និងខ្វះមិនបាននេះនៅក្នុងព្រះគម្ពីរ។ ខ្ញុំសង្ឃឹមថា នៅពេលដែលលោកអ្នកអានសៀវភៅនេះ នោះលោកអ្នកនឹងមានចិត្តស្ងប់ស្ងែងជាថ្មីម្តងទៀតចំពោះសេចក្តីបង្រៀនអំពីការរាប់ជាសុចរិត ហើយខ្ញុំសូមអធិស្ឋានឲ្យមនុស្សកាន់តែច្រើននាក់ទៀត (ប្រហែលជាថែមទាំងរូបអ្នកផ្ទាល់ផង) គឺឲ្យអាចនឹងបានស្គាល់អំពីសេចក្តីអំណរនៃការបានសុចរិតជាមួយនឹងព្រះជាម្ចាស់»។

**Matthew Boswell**

Hymnwriter; Pastor, The Trails Church, Celina, Texas

plovpit.com

# បានសុចរិតជាមួយព្រះជាម្ចាស់

លោកគ្រូ ម៉ៃឃើល រីវស៍

*Right With God*
*បានសុចរិតជាមួយព្រះជាម្ចាស់*
© 2022 by Michael Reeves
រក្សាសិទ្ធិ ©2023 by Tim Chester

www.UnionPublishing.org
Bridgend, Wales, United Kingdom

This edition in Khmer copyright ©2026 by ACTION Cambodia Organization

All rights reserved.
រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៦
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ជឿន ជីវិចន្ទា
ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ឯក សត្យា, លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក ឡង់ គីមឡុង, លោកស្រី ឡូញ ស្រីរ័ត្ន, កញ្ញា រិន ខារីសា និងលោកស្រី ចាវ ប៊ុនរី
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ើល ណាថាន និងលោក ខែម បូឡុង

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយពន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

*For ordering information please visit: plovpitshop.com*
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ *plovpitshop.com*

បោះពុម្ពលើកទី១ ចំនួន ៣.០០០ ក្បាល ២០២៦ នៃគ.ស.
ISBN : 978-9924-566-33-5

# មាតិកា


១ សេចក្ដីស្រឡាញ់ដែលរំដោះឲ្យមានសេរីភាព ៩

២ ការរាប់ជាសុចរិតផ្លាស់ប្ដូរអ្វីៗទាំងអស់ ២១

៣ សម្លៀកបំពាក់ថ្មី ២៩

៤ ការប្ដូរគ្នាដ៏គួរឲ្យភ្ញាក់ផ្អើល ៣៩

៥ មែនហើយ ប៉ុន្តែ...តើយើងពន្យល់ពីការប្រព្រឹត្ត និងជំនឿយ៉ាងដូចម្ដេច? ៤៩

៦ មែនហើយ ប៉ុន្តែ...តើយើងនៅបន្តធ្វើបាបទៀតឬ? ៥៥

៧ មែនហើយ ប៉ុន្តែ...តើខ្ញុំអាចដឹងជាក់បានដោយរបៀបណា? ៦១

៨ «ហាលេលូយ៉ា! ព្រះអង្គសង្គ្រោះអ្វីក៏អស្ចារ្យយ៉ាងនេះ!» ៦៧

ឯកសារយោង ៧៣

លិបិក្រមតាមព្រះគម្ពីរ ៧៧

អំពីក្រុម Union ៨១

«តើជីវិតមានន័យដែរឬទេ?»

មានន័យ!

«តើខ្ញុំមានតម្លៃអ្វីខ្លះ?»

មាន!

«តើខ្ញុំអាចទទួលបានការអត់ទោសពីអំពើបាបបានដែរឬទេ?»

អាច!

«តើគេអាចស្គាល់ខ្ញុំ និងស្រឡាញ់បានដែរឬទេ?»

បាន! គឺពិតជាអាចបានមែន។ គឺអាចរាប់លានដង!

មានព្រះអម្ចាស់មួយដែលទ្រង់ឱនលំទោនចុះមក។ ទ្រង់លូកព្រះហស្តរបស់ទ្រង់ ហើយទ្រង់ខ្សឹបប្រាប់យើងថា៖ «កុំឲ្យខ្លាចឡើយ។»

ព្រះយេស៊ូវគឺជាព្រះអង្គនោះ!

Emma Scrivener
*A New Name: Grace and Healing for Anorexia*

១

# សេចក្ដីស្រឡាញ់ដែលរំដោះឲ្យមានសេរីភាព

តើលោកអ្នកធ្វើឲ្យនរណាម្នាក់ស្រឡាញ់ និងទទួលយកលោកអ្នកដោយរបៀបណា? គឺដោយលោកអ្នកព្យាយាមធ្វើឲ្យខ្លួនឯងកាន់តែមានភាពទាក់ទាញ តើត្រឹមត្រូវទេ? លោកអ្នកព្យាយាមធ្វើឲ្យខ្លួនឯងកាន់តែគួរឲ្យស្រឡាញ់ និងមានភាពទាក់ទាញ។ នោះហើយជាអ្វីដែលគ្រប់ទាំងការផ្សាយពាណិជ្ជកម្មបានប្រាប់យើងឲ្យធ្វើ។ វាជាសារដ៏ឥតឈប់ឈរនៃប្រព័ន្ធផ្សព្វផ្សាយសង្គម។

ក៏ប៉ុន្តែ ចំពោះព្រះជាម្ចាស់វិញ គឺវាផ្ទុយស្រឡះពីនេះ។ ចំពោះព្រះជាម្ចាស់ មនុស្សដែលខ្ទេចខ្ទាំ និងបរាជ័យ «គឺស្រស់ស្អាត ពីព្រោះពួកគេទទួលបានការស្រឡាញ់។ ពួកគេមិនបានទទួលការស្រឡាញ់ ដោយព្រោះពួកគេស្រស់ស្អាតនោះទេ» (ដូចដែលលោកម៉ាធិន លូសើរ បានលើកឡើង)។ នេះមានន័យថា ព្រះជាម្ចាស់មិនមែនស្រឡាញ់មនុស្ស ដោយព្រោះពួកគេបាន

ដោះស្រាយបញ្ហាផ្សេងៗរបស់ពួកគេនោះទេ៖ ព្រះអង្គស្រឡាញ់មនុស្សដែលបរាជ័យ ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ជួយពួកគេឲ្យលូតលាស់។

នេះជាកូនសៀវភៅមួយក្បាល ស្ដីអំពីការបានសុចរិតជាមួយនឹងព្រះជាម្ចាស់។ នេះជាសៀវភៅអំពីចំណុចស្នូលនៃដំណឹងល្អរបស់គ្រីស្ទបរិស័ទ៖ ការរាប់ជាសុចរិត។

មានទីបន្ទាល់ដូចៗគ្នាជាបន្តបន្ទាប់ជាច្រើនសតវត្សរ៍មកហើយ។ មនុស្សដែលបានរៀនអំពីសេចក្ដីពិតនេះមានអារម្មណ៍ថា ពួកគាត់បានទទួលការរំដោះឲ្យមានសេរីភាព។ លោក វៀលឡាម ថិនដិល (William Tyndale) បានហៅសេចក្ដីពិតនេះថាជា «ដំណឹងនៃអំណរ និងរីករាយ ដែលធ្វើឲ្យចិត្តមនុស្សសប្បាយ និងធ្វើឲ្យគាត់ច្រៀង រាំ និងលោតកញ្ឆេងដោយអំណរ»។ លោក ថូម៉ាស់ ប៊ីលនី (Thomas Bilney) បានមានប្រសាសន៍ថា សេចក្ដីពិតនេះបានផ្ដល់ឲ្យគាត់នូវ «ការកម្សាន្តចិត្ត និងសន្តិភាពដ៏អស្ចារ្យ ហើយវាបានធ្វើឲ្យឆ្អឹងដ៏ហត់នឿយរបស់ខ្ញុំលោតកញ្ឆេងដោយអំណរ»។ លោក ឆាលស៍ វែសលី (Charles Wesley) បានច្រៀងថា «ច្រវាក់របស់ទូលបង្គំបានកាត់ផ្ដាច់ ចិត្តរបស់

ទូលបង្គំមានសេរីភាព ហើយទូលបង្គំបានក្រោកឡើង ដើរទៅមុខ ហើយដើរតាមទ្រង់»។

នៅថ្ងៃនេះ ខ្ញុំសង្ឃឹមថា លោកអ្នកនឹងរកឃើញនូវការរំដោះឲ្យមានសេរីភាពបែបនេះ ប្រសិនបើលោកអ្នកមិនទាន់បានស្គាល់សេចក្តីពិតបែបនេះនៅឡើយទេ។

## ការចូលទៅនគរឋានសួគ៌–ប៉ុន្តែតើត្រូវចូលដោយរបៀបណា?

កាលលោក ម៉ធិន លូសើរ នៅវ័យក្មេងនៅឡើយ គាត់មិនបានដឹងអំពីរបៀបឲ្យបានសុចរិតជាមួយនឹងព្រះជាម្ចាស់ទេ ហើយការនេះបានធ្វើឲ្យគាត់មិនសប្បាយចិត្តជាខ្លាំង។ ប៉ុន្តែ នោះមិនមែនជាកំហុសរបស់គាត់នោះទេ ពីព្រោះគាត់ទទួលការបង្រៀនតាំងពីតូចមកឲ្យជឿថា ការទទួលបានសុចរិតជាមួយនឹងព្រះជាម្ចាស់គឺតាមរយៈដំណើរការនៃការធ្វើឲ្យប្រសើរឡើងនៅខាងក្នុង។ នេះមានន័យថា ព្រះជាម្ចាស់ដាក់ព្រះគុណរបស់ទ្រង់ទៅក្នុងចិត្តយើង ធ្វើឲ្យពួកគេកាន់តែបរិសុទ្ធ និងត្រៀមខ្លួនសម្រាប់នគរស្ថានសួគ៌បន្តិចម្តងៗ កាន់តែសុចរិតបន្តិចម្តងៗ (ឬថា *«រាប់ជាសុចរិត»*)។

ការបង្រៀននេះមិនគួរធ្វើឲ្យលោក ម៉ធិន លូសើរ ភ្ញាក់ផ្អើល និងមិនសប្បាយចិត្តទេ។ មានទេវវិទូម្នាក់បាននិយាយថា «ព្រះជាម្ចាស់នឹងមិនបដិសេធព្រះគុណទ្រង់ចំពោះអស់អ្នកដែលខិតខំអស់ពីសមត្ថភាពរបស់ខ្លួននោះទេ»។ ប៉ុន្តែ លោក ម៉ធិន មិនប្រាកដទេថា៖ តើគាត់បានខិតខំអស់ពីសមត្ថភាពរបស់គាត់ហើយឬនៅ? តើគាត់ទទួលបាន «ការរាប់ជាសុចរិត» ឬបានល្អប្រសើរល្មមគ្រប់គ្រាន់ ដើម្បីត្រៀមខ្លួនសម្រាប់នគរឋានសួគ៌ហើយ

ឬនៅ? ចុះបើគាត់ត្រូវស្លាប់ភ្លាមៗនោះ? តើគាត់នឹងបានល្អគ្រប់គ្រាន់សម្រាប់ឲ្យអាចចូលនគរឋានសួគ៌បានដែរឬទេ?

## «ខ្ញុំនឹងធ្វើជាសង្ឃ»

«ការល្បងលជំនឿរបស់លោក ម៉ធិន បានកើតឡើងនៅពេលដែលគាត់មានអាយុម្ភៃមួយឆ្នាំ ខណៈពេលដែលគាត់កំពុងតែធ្វើដំណើរទៅសាកលវិទ្យាល័យរបស់គាត់។ ក្នុងអំឡុងពេលកំពុងមានព្យុះកន្ត្រាក់មួយបានកើតឡើងភ្លាមៗ នោះក៏មានរន្ទះបាញ់ដែលធ្វើឲ្យគាត់ដួលលើដីទៀតផង។ ដោយមានការភ័យខ្លាចក្នុងការស្លាប់ និងអ្វីដែលអាចនឹងកើតឡើងបន្ទាប់ពីស្លាប់ នោះគាត់ក៏បានស្រែកឡើងថា «សន្ត អាន់ (Saint Anne) សូមជួយខ្ញុំផង! ហើយខ្ញុំនឹងធ្វើជាសង្ឃ!»។ គាត់មិនហ៊ានសុំជំនួយពីព្រះជាម្ចាស់នោះទេ ពីព្រោះគាត់គិតថា ព្រះដ៏បរិសុទ្ធនឹងមិនស្តាប់មនុស្សមានបាបដូចជាគាត់នោះឡើយ។ ផ្ទុយទៅវិញ គាត់បានអធិស្ឋានទៅកាន់សន្ត អាន់ ដែលជាម្តាយរបស់នាង ម៉ារា។ គាត់សង្ឃឹមថា សន្តនោះនឹងនិយាយទៅកាន់នាង ម៉ារា ជំនួសគាត់ ហើយថានាង ម៉ារី នឹងនិយាយទៅកាន់ព្រះយេស៊ូវជំនួសគាត់។

ដូច្នេះ បន្ទាប់ពីគាត់បានរួចជីវិតពីព្យុះកន្ត្រាក់នោះ មកយុវជន ម៉ធិន ក៏បានចាប់ផ្ដើមជីវិតជាសង្ឃ។ ក្នុងន័យម្យ៉ាង គាត់ស្រឡាញ់ការធ្វើជាសង្ឃណាស់។ ក្នុងន័យម្យ៉ាងទៀតនោះគឺថា ការភ័យខ្លាចដ៏ធំបំផុតរបស់គាត់គឺការស្លាប់ ហើយបន្ទាប់មកត្រូវឈរនៅចំពោះព្រះជាម្ចាស់ ដែលជាចៅក្រមរបស់គាត់។ ប៉ុន្តែ ការធ្វើជាសង្ឃបានផ្ដល់ឲ្យគាត់នូវអ្វីមួយដែលគាត់គិតថាជាឱកាសមាស ពោលគឺគាត់អាចធ្វើឲ្យខ្លួនគាត់កាន់តែមានភាពទាក់ទាញចំពោះព្រះជាម្ចាស់ ហើយសង្ឃឹមថានឹងទទួលបានសេចក្ដីស្រឡាញ់ពីទ្រង់។

ហើយគាត់បានខំធ្វើការយ៉ាងខ្លាំង។ ជារៀងរាល់ពីរបីម៉ោងម្ដង គាត់បានចាកចេញពីបន្ទប់អារាមដ៏តូចរបស់គាត់ ហើយទៅចូលរួមកម្មពិធីថ្វាយបង្គំនៅក្នុងវិហារ។ កម្មវិធីថ្វាយបង្គំលើកទីមួយ គឺធ្វើឡើងនៅពាក់កណ្ដាលអធ្រាត្រ។ បន្ទាប់មក គាត់បានចូលរួមកម្មវិធីថ្វាយបង្គំមួយទៀតនៅម៉ោងប្រាំមួយព្រឹក បន្ទាប់មកម្ដងទៀតនៅម៉ោងប្រាំបួន ម្ដងទៀតនៅម៉ោងដប់ពីរ និងបន្តបន្ទាប់ទៀត។ ជាញឹកញាប់ គាត់មិនបានញ៉ាំអាហារ ឬទឹករយៈពេលបីថ្ងៃជាប់ៗគ្នា។ គាត់បានត្រៀមខ្លួនរួចជាស្រេច ដើម្បីបង្កកខ្លួននៅក្នុងភាពត្រជាក់នៃរដូវរងាដោយចេតនា ដោយសង្ឃឹមថាការធ្វើបែបនោះនឹងធ្វើឲ្យ

ព្រះជាម្ចាស់សប្បាយព្រះទ័យ។ ដោយសារតែមានការជំរុញក្នុងចិត្តឲ្យលន់តួអំពើបាប នោះគាត់តែងតែធ្វើឲ្យពួកសង្ឃជាច្រើនដែលបានស្ដាប់ការលន់តួរបស់គាត់អស់កម្លាំងជាខ្លាំង ដោយគាត់ចំណាយពេលរហូតដល់ប្រាំមួយម៉ោងក្នុងមួយពេល ដើម្បីរៀបរាប់អំពើបាបថ្មីៗបំផុតរបស់គាត់។

## «ប៉ុន្តែ តើខ្ញុំល្អគ្រប់គ្រាន់ហើយឬនៅ?»

កាលណាលោក ម៉ាធិន ធ្វើកាន់តែច្រើន នោះគាត់ក៏កាន់តែមានអារម្មណ៍ថាមានបញ្ហា។ តើគាត់មានភាពស្មោះត្រង់គ្រប់គ្រាន់ហើយឬនៅ? តើសេចក្ដីជំរុញចិត្តខាងក្នុងរបស់គាត់ត្រឹមត្រូវដែរឬទេ? លោក ម៉ាធិន ចាប់ផ្ដើមគិតកាន់តែស៊ីជម្រៅអំពីខ្លួនឯង។ គាត់ចាប់ផ្ដើមមានអារម្មណ៍ថាភាពកខ្វក់ខាងសីលធម៌ និងកង្វះខាងភាពទាក់ទាញរបស់គាត់ចំពោះព្រះជាម្ចាស់គឺធ្ងន់ធ្ងរជាងសកម្មភាពរបស់គាត់ទៅទៀត។ គាត់បានមើលឃើញខ្លួនឯងថាជាបុរសម្នាក់ដែលផ្ដោតតែលើខ្លួនឯង ហើយជាទូទៅគឺអាត្មានិយមណាស់។ អាកប្បកិរិយាល្អ និងសកម្មភាពបែបសាសនាទាំងអស់របស់គាត់គឺគ្រាន់តែលាក់បាំងបញ្ហាតែប៉ុណ្ណោះ មិនមែនធ្វើឲ្យវាមានភាពប្រសើរឡើងនោះទេ។

អ្វីដែលអាក្រក់ជាងនេះទៅទៀតគឺលោក ម៉ធិន ដែលជាសង្ឃ បានចាប់ផ្តើមមើលឃើញព្រះជាម្ចាស់ក្នុងលក្ខណៈថាជាមេដឹកនាំផ្តាច់ការដែលគ្មានសេចក្តីស្រឡាញ់ ដែលទាមទារតែភាពល្អឥតខ្ចោះ ហើយទ្រង់ដាក់ទណ្ឌកម្មទៀតផង។ លោកបានសរសេរថា «ទោះបីជាខ្ញុំបានរស់នៅជាសង្ឃដោយមិនធ្វើអ្វីខុសក៏ដោយ ក៏ខ្ញុំមានអារម្មណ៍ដូចជាមនុស្សមានបាបនៅចំពោះព្រះជាម្ចាស់ ដោយមានមនសិការមិនសប្បាយចិត្តជាខ្លាំងផងដែរ»។ ក្រោយមកលោកក៏បានសរសេរថែមទៀតថា «ខ្ញុំមិនបានស្រឡាញ់ព្រះជាម្ចាស់ទេ។ តាមពិតទៅ ខ្ញុំស្អប់ព្រះដ៏សុចរិតដែលតែងតែដាក់ទោសដល់មនុស្សមានបាបណាស់។ ហើយទោះបើខ្ញុំមិនបានប្រមាថដល់ព្រះជាម្ចាស់ក៏ដោយ ក៏ខ្ញុំពិតជាបានរអ៊ូរទាំយ៉ាងខ្លាំងដោយសម្ងាត់ថា *ខ្ញុំខឹងនឹងព្រះជាម្ចាស់ណាស់*»។

នៅក្នុងស្ថានភាពដ៏ខ្មៅងងឹតនោះ គាត់បានរកឃើញនូវអ្វីមួយដែលរីករាយ។

## «ខ្ញុំបានចាប់ផ្តើមយល់»

នៅពេលគាត់កំពុងអានព្រះគម្ពីរនៅក្នុងបន្ទប់ នោះគាត់បានព្យាយាមយល់អំពីអ្វីដែលសាវ័ក ប៉ុល ចង់មានន័យ

នៅពេលដែលលោកបានសរសេរនៅក្នុងសំបុត្រទៅកាន់ពួកអ្នកជឿនៅទីក្រុងរ៉ូមយ៉ាងដូច្នេះថា៖

> «ដ្បិតសេចក្តីសុចរិតនៃព្រះ បានសម្តែងមកក្នុងដំណឹងល្អនោះ ដោយសារសេចក្តីជំនឿ ហើយឲ្យបានសេចក្តីជំនឿចម្រើនច្រើនឡើងផង ដូចមានសេចក្តីចែងទុកមកថា “មនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ”» (រ៉ូម ១:១៧)។

តើការនោះមានន័យយ៉ាងម៉េច? ហើយតើ «សេចក្តីសុចរិតនៃព្រះ» ជាអ្វី? តើនេះមានន័យថាព្រះទ្រង់ល្អឥតខ្ចោះ ហើយខ្ញុំមិនមែនល្អឥតខ្ចោះនោះទេ ហើយជាលទ្ធផលខ្ញុំមិនអាចនៅជាមួយទ្រង់បានមែនឬ? នោះជាអ្វីដែលលោក ម៉ធិន បានគិត។ ប៉ុន្តែ «នៅទីបំផុត» គាត់បានសរសេរថា៖

> «ខ្ញុំចាប់ផ្តើមយល់ថា សេចក្តីសុចរិតនៃព្រះគឺជាអ្វីដែលអនុញ្ញាតឲ្យមនុស្សសុចរិតរស់នៅបាន។ វាគឺជាអំណោយទានមួយពីព្រះជាម្ចាស់ ហើយជំនឿគឺជាអំណោយទាននេះ»។

## «ព្រះទ្រង់ស្រឡាញ់ខ្ញុំជាមុន»

ការយល់ឃើញបែបនេះបានផ្លាស់ប្តូរអ្វីៗទាំងអស់។ វាប្រៀបដូចជាពិភពលោកទាំងមូលរបស់លោក ម៉ធិន បានក្រឡាប់ចាក់។ លោក ម៉ធិន បានយល់ឃើញថា ព្រះជាម្ចាស់មិនទាមទារឲ្យយើងខំប្រឹងធ្វើអ្វីម្យ៉ាង ដើម្បីទទួលបានសេចក្តីស្រឡាញ់ និងការស្គាល់ពីទ្រង់នោះទេ។ សេចក្តីសុចរិតរបស់ព្រះជាម្ចាស់គឺជាអ្វីមួយដែលទ្រង់ចែករំលែកជាមួយនឹងយើង ដែលប្រៀបដូចជាអំណោយទានមួយ។ យើងអាចទទួលបាននូវការទទួលស្គាល់នៅចំពោះព្រះជាម្ចាស់ ការអត់ទោស និងសេចក្តីមេត្រីដោយជំនឿ ឬការទុកចិត្តដ៏សាមញ្ញ។ យើងមិនមែនខំព្យាយាមប្រព្រឹត្តអំពើល្អ ដើម្បីទទួលបានការឯកភាពពីព្រះជាម្ចាស់នោះទេ។

អ្វីដែលលោក ម៉ធិន បានរកឃើញនៅក្នុងព្រះគម្ពីរគឺជាដំណឹងដ៏ល្អណាស់៖ ព្រះដែលមានព្រះទ័យសន្តោស និងសប្បុរស។ ព្រះអង្គនេះមិនទាមទារឲ្យមនុស្សព្យាយាមធ្វើឲ្យខ្លួនឯងមានភាពទាក់ទាញមុនពេលដែលទ្រង់ស្រឡាញ់ពួកគេនោះទេ។ ទ្រង់បានស្រឡាញ់ពួកគេជាមុន។ លោក ម៉ធិន បានយល់ឃើញថា ជំនួសឲ្យការជឿទុកចិត្តលើការខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើជាមនុស្សល្អ គឺលោកអាចទទួលយកការសន្យារបស់ព្រះជាម្ចាស់

បានយ៉ាងសាមញ្ញ។ នោះការតយុទ្ធ និងការថប់បារម្ភទាំងអស់របស់គាត់អាចជំនួសដោយទំនុកចិត្ត និងសន្តិភាពដ៏រីករាយ។ លោក ម៉ធិន បានមានប្រសាសន៍ដោយអំណរយ៉ាងខ្លាំងថា៖ «នៅពេលនោះ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានកើតជាថ្មីទាំងស្រុងម្តងទៀត ហើយបានចូលទៅក្នុងស្ថានសួគ៌ តាមរយៈទ្វារចំហ»។

២

# ការរាប់ជាសុចរិតផ្លាស់ប្តូរអ្វីៗទាំងអស់

លោក ម៉ធិន លូសើរ ទទួលបានការផ្លាស់ប្តូរ នៅពេលដែលលោកបានអានកណ្ឌគម្ពីររ៉ូម។ ចូរស្វែងយល់ពីការនេះបន្ថែមទៀត។

សំបុត្ររបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំនៅទីក្រុងរ៉ូមពន្យល់អំពីរបៀប ដើម្បីឲ្យបានត្រឡប់ទៅជាសុចរិតជាមួយនឹងព្រះជាម្ចាស់វិញ។ នៅក្នុងបីជំពូកដំបូងសាវ័កប៉ុល បានលើកឡើងថា មនុស្សទាំងអស់ (ដែលមានន័យថាយើងទាំងអស់គ្នា) មានទោសដោយសារអំពើបាប ហើយត្រូវបានព្រះជាម្ចាស់ថ្កោលទោស។ «គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង» (រ៉ូម ៣:១០)។

ប៉ុន្តែ សូមចាំបន្តិច នៅមានអ្វីផ្សេងទៀត៖

> «ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ» (រ៉ូម ៣:២៣-២៤)។

ដូច្នេះ តើសាវ័ក ប៉ុល ចង់មានន័យយ៉ាងណាពេលគាត់ប្រើពាក្យថា «បានរាប់ជាសុចរិត»? នៅក្នុងកណ្ឌគម្ពីរ រ៉ូម ជំពូក៤ លោកបានពន្យល់អំពីអត្ថន័យនៃពាក្យនេះដោយប្រើលោក អ័ប្រាហាំ–ជាឧទាហរណ៍៖ បានពណ៌នាអំពីលោក អ័ប្រាហាំ ថាជាបិតានៃអស់អ្នកដែលស្មោះត្រង់។

> «បើដូច្នេះ យើងនឹងថា លោកអ័ប្រាហាំ ជាឰយុកោយើង បានអ្វីខ្លះ ខាងឯសាច់ឈាម ដ្បិតបើសិនណាជាលោកអ័ប្រាហាំបានរាប់ជាសុចរិត ដោយការដែលលោកប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែនចំពោះព្រះទេ តើគម្ពីរថាដូចម្តេច គម្ពីរថា “អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក” រីឯអ្នកណាដែលធ្វើការ នោះរង្វាន់មិនរាប់ជាគុណរបស់ចៅហ្វាយទេ គឺទុកជាថ្លៃឈ្នួលវិញទេ

> តើ តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឲ្យមនុស្សទមិលល្មើសបានសុចរិត នោះសេចក្ដីជំនឿរបស់អ្នកនោះបានរាប់ទុកជាសេចក្ដីសុចរិតវិញ ដូចជាហ្លួងដាវីឌបានសំដែងពីសណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា “មានពរហើយអ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឲ្យ និងបាបខ្លួនបានគ្របបាំង មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ”»
> (រ៉ូម ៤:១-៨)។

លោក អ័ប្រាហាំ គ្មានអ្វីដែលត្រូវអួតបាននោះទេ។ ព្រះជាម្ចាស់មិនបានចាត់ទុកលោកថាជាមនុស្សសុចរិតនោះទេ ពីព្រោះលោកមិនមែនជាមនុស្សសុចរិតដោយខ្លួនឯងឡើយ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានបង្ហាញសេចក្តីសប្បុរសរបស់ទ្រង់ដោយទ្រង់ធ្វើជាព្រះដែល «ប្រោសឲ្យមនុស្ស*ទមិលល្មើស*បានជាសុចរិត (ខ. ៥)។ ជាជាងឲ្យលោក អ័ប្រាហាំ ខំប្រឹងក្លាយជាមនុស្សសុចរិតដោយខ្លួនឯង ដូចដែលកណ្ឌគម្ពីរ លោកុប្បត្តិ ១៥:៦ (ដែលបានលើកឡើងនៅក្នុង ខ.៣ ខាងលើ) បានប្រាប់យើង លោកគ្រាន់តែ «ជឿដល់ព្រះអង្គ» ហើយត្រូវបាន*រាប់*ជាសុចរិតដោយសារតែការធ្វើដូច្នេះ។

ការរាប់ជាសុចរិតមានន័យថា ព្រះជាម្ចាស់បានប្រកាសដោយសប្បុរសថាមនុស្សមានបាបគឺបាន «សុចរិត» ហើយ។ នេះមានន័យថា គាត់ទទួលបានការប្រកាស/រាប់ថាជាសុចរិត មិនមែនគាត់ត្រូវផ្លាស់ប្តូរបន្តិចម្តងៗ ឲ្យក្លាយជាមនុស្សសុចរិតនោះទេ។ ការបានរាប់ជាសុចរិតមិនដែលមានន័យថា «ការក្លាយជាសុចរិតបន្តិចម្តងៗនោះទេ»។ «ការរាប់ជាសុចរិត» គឺជាពាក្យផ្លូវច្បាប់ដែលជាផ្នែកមួយនៃភាសាដែលប្រើដោយចៅក្រមនៅក្នុងបន្ទប់សវនាការដែលប្រកាសថា «មានទោស» ឬ «គ្មានទោស»។

ឬក៏ថា សូមគិតអំពីរបៀបដែលយើងប្រើពាក្យនេះជារៀងរាល់ថ្ងៃ។ សូមស្រមៃថា ឪពុករបស់លោកអ្នកបានឃើញលោកអ្នកកំពុងតែធ្វើអ្វីមួយដែលហាក់ដូចជាគួរឲ្យសង្ស័យបន្តិច។ ដោយសារតែគាត់ជាមនុស្សមានហេតុមានផល នោះគាត់មិនស្រែកដាក់លោកអ្នកភ្លាមៗនោះទេ។ ផ្ទុយទៅវិញ គាត់សួរថា «តើកូនអាចពន្យល់ពីសកម្មភាពរបស់កូនបានទេ? តើកូនអាចពន្យល់អំពីមូលហេតុដែលកូនធ្វើបែបនោះបានទេ?» តើគាត់កំពុងសួរនាំរកអ្វី? គាត់មិនបានសុំឲ្យលោកអ្នកត្រឡប់ទៅអតីតកាលវិញ ហើយសុំឲ្យលោកអ្នកធ្វើឲ្យអ្វីដែលលោកអ្នកបានធ្វើកន្លងមកកាន់តែប្រសើរឡើងនោះទេ។

នោះមិនមែនជាអត្ថន័យនៃ «ការបង្ហាញអំពីភាពត្រឹមត្រូវ ឬក៏ការរាប់ជាសុចរិត» ទេ។ គាត់ចង់ឲ្យលោកអ្នកឆ្លើយការពារសកម្មភាពរបស់លោកអ្នក ដើម្បីបង្ហាញថាវាជាសកម្មភាពត្រឹមត្រូវ និងសមហេតុសមផលដែលលោកអ្នកបានធ្វើ ទោះបីជាមើលទៅវាហាក់បីដូចជាមិនទំនងក៏ដោយ។ «ការរាប់ជាសុចរិត» គឺនិយាយអំពីការវាយតម្លៃ ការប្រកាស និងសាលក្រម។

នៅក្នុងព្រះគម្ពីរក៏ដូចគ្នានេះដែរ។ យើងទទួលបានការរាប់ជាសុចរិតនៅពេលដែលព្រះជាម្ចាស់ប្រកាសថា យើងបានសុចរិតនៅចំពោះទ្រង់។ នៅក្នុងព្រះគម្ពីរ មនុស្សសុចរិតមិនមែនជាមនុស្សដែលធ្វើអំពើល្អច្រើន ឬមិនធ្លាប់ធ្វើបាបសោះនោះទេ។ សាវ័ក ប៉ុល បានសរសេរថា៖ «តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឲ្យមនុស្សទមិលល្មើសបានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្តីសុចរិតវិញ» (៤.៥)។ មនុស្សសុចរិតមិនមែនជាអ្នកដែលបានជួសជុលជីវិតរបស់ពួកគេឡើងវិញនោះទេ ប៉ុន្តែជាមនុស្សមានបាបដ៏ទមិលល្មើស ដែលព្រះជាម្ចាស់បានប្រកាសថា «សុចរិត»។ ការរាប់ជាសុចរិតគឺជា «សណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្ត» (៤.៦)។

បន្ទាប់មក សាវ័ក ប៉ុល បានបន្តបញ្ជាក់អះអាងអំពីគំនិតរបស់លោក ដោយប្រើពាក្យរបស់ស្តេច ដាវីឌ ក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ៣២:១-២៖

> «មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឲ្យ និងបាបខ្លួនបានគ្របបាំង មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ» (រ៉ូម ៤:៧-៨ ដោយសំដៅទៅលើ ទំនុកតម្កើង ៣២:១-២)។

ស្តេច ដាវីឌ បានឈ្វេងយល់ឃើញថា មនុស្សដែលមានពរមិនមែនជាមនុស្សដែលគ្មានបាបនោះទេ។ មនុស្សដែលមានពរគឺជាអ្នកដែលអំពើបាបរបស់ខ្លួនទទួលបាន «ការគ្របបាំង» ហើយព្រះអម្ចាស់ក៏នឹងមិនយកអំពើបាបរបស់គាត់មកទាស់នឹងគាត់ឡើយ។

«ខ្ញុំបានឃើញជាលើកដំបូងក្នុងជីវិតរបស់ខ្ញុំថា ព្រះគ្រីស្ទបានដកយកបន្ទុកនៃអំពើអាក្រក់របស់ខ្ញុំចេញ។ ព្រះអង្គបានទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះសកម្មភាពខុសឆ្គងទាំងអស់របស់ខ្ញុំ។ អ្វីៗដ៏អាក្រក់ទាំងអស់ត្រូវបានដាក់លើព្រះកេសដែលគ្មានបាបរបស់ទ្រង់។ ព្រះអង្គទទួលយកវាដោយស្ម័គ្រព្រះទ័យ ដើម្បីឲ្យខ្ញុំអាចមានសេរីភាព។

ខ្ញុំគ្មានសេចក្តីអាម៉ាស់ក្នុងការនិយាយថា សេចក្តីស្រឡាញ់ដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនប្រភេទនេះធ្វើឲ្យខ្ញុំឃុំទេ។ ខ្ញុំជឿជាក់ថា ខ្ញុំរឹងមាំមែន ប៉ុន្តែខ្ញុំក៏បានយំដែរ»–លោក ម៉ៃឃើល គ្រីន, «បង្ខំក្នុងចិត្តដោយអំណរ៖ ការឆ្លុះបញ្ចាំងរបស់អ្នកផ្សាយដំណឹងល្អពេញមួយជីវិត»

លោក Michael Green
*Compelled by Joy: The Reflections of a Lifelong Evangelist*

៣

# សម្លៀកបំពាក់ថ្មី

ប៉ុន្តែ តើការនេះអាចកើតឡើងបានដោយរបៀបណា? តើព្រះជាម្ចាស់អាចហៅមនុស្សមានបាបថា «សុចរិត» បានយ៉ាងដូចម្ដេច? ចម្លើយនោះគឺសាមញ្ញទេ ប៉ុន្តែមានភាពជ្រាលជ្រៅណាស់៖ មានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ។

ព្រះយេស៊ូវបានទទួលយកទោសប្រហារជីវិតជំនួសយើងនៅលើឈើឆ្កាង ដោយព្រោះអំពើបាបរបស់យើង។ សូមគិតអំពីការនេះមួយភ្លែត–នេះគឺជារឿងផ្ទាល់ខ្លួន។ អ្នកណាដែលជឿលើទ្រង់បានក្លាយជាផ្នែកមួយនៃរូបកាយរបស់ទ្រង់ ហើយឆ្លងកាត់អ្វីដែលបានកើតឡើងចំពោះរូបកាយរបស់ទ្រង់។ យើងបានស្លាប់ជាមួយនឹងទ្រង់។ អត្តសញ្ញាណចាស់របស់យើងត្រូវបានជាប់ឆ្កាង និងបញ្ចុះក្នុងផ្នូរជាមួយព្រះគ្រីស្ទ (កូឡុស ២:១២; រ៉ូម ៦:៣)។ ឥឡូវនេះ ការសុគតរបស់ទ្រង់មិនមែនជាអំពើបាបរបស់យើងទៀតទេ ប៉ុន្តែគឺជាអតីតកាលរបស់យើងវិញ។

បន្ទាប់ពីព្រះអង្គបានសុគតនៅលើឈើឆ្កាង យើងឃើញយ៉ាងច្បាស់ថា ព្រះអង្គមានសេចក្តីសុចរិតច្រើនជាងអំពើបាបនៅក្នុងយើង។ ចាប់តាំងពីព្រះអង្គបានផ្ទុកអំពើបាបរបស់យើងរួចមក នោះសេចក្តីស្លាប់មិនមានអំណាចលើទ្រង់តទៅទៀតទេ។ នៅពេលដែលព្រះអង្គបានសម្លាប់អំពើបាប និងសេចក្តីស្លាប់រួចហើយ នោះសេចក្តីស្លាប់លែងមានសិទ្ធិលើទ្រង់តទៅទៀត។ នៅពេលដែលព្រះរាជបុត្រាបានបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ពេញលេញហើយ នោះព្រះវរបិតាក៏មិនអាចទុកឲ្យព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់នៅសុគតទៀតបានទេ។ ដូច្នេះ ព្រះអង្គបានបញ្ជាក់អះអាងថា ព្រះរាជបុត្រាត្រឹមត្រូវ–ឬ «បានរាប់ជាសុចរិត»–ដោយប្រកាសថា ព្រះអង្គសក្តិសមនឹងបានជីវិតយ៉ាងពេញលេញ (១ធីម៉ូថេ ៣:១៦)។

ហើយនៅពេលដែលព្រះវរបិតាបានរាប់ព្រះគ្រីស្ទថាជាសុចរិត ហើយប្រកាសថាទ្រង់ស័ក្តិសមនឹងបានជីវិតដោយព្រះវរបិតារបស់ទ្រង់ នោះព្រះអង្គក៏ «បានប្រោសឲ្យ [ព្រះគ្រីស្ទ] មានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឲ្យយើងរាល់គ្នាបានរាប់ជាសុចរិត» (រ៉ូម ៤:២៥)។ ព្រះអង្គបានតាំងឡើងទុកជា «សេចក្តីសុចរិតរបស់យើង» (១កូរិនថូស ១:៣០; យេរេមា ២៣:៦)។ អ្នកជឿទាំង

អស់គឺជាអរយរៈនៃរូបកាយរបស់ទ្រង់ ហើយមានចំណែកក្នុងការរាប់ជាសុចរិតដែលផ្តល់មកនូវជីវិត ដែលទ្រង់បានទទួលនៅព្រឹកថ្ងៃបុណ្យព្រះអង្គមានព្រះជន្មរស់។ ដូច្នេះ នៅក្នុងទ្រង់ យើងទទួលបានជីវិតថ្មី ហើយយើងបានត្រឡប់ទៅជាសេចក្តីសុចរិតដ៏ពិតរបស់ព្រះជាម្ចាស់ (២កូរិនថូស ៥:២១)។

នោះហើយជាមូលហេតុដែលសាវ័ក ប៉ុល បានសរសេរអំពីការចង់ «បានព្រះគ្រីស្ទវិញ ហើយឲ្យគេបានឃើញខ្ញុំនៅក្នុងទ្រង់ ដោយសេចក្តីសុចរិតដែលមកពីសេចក្តីជំនឿដល់ព្រះគ្រីស្ទ មិនមែនដោយសេចក្តីសុចរិតរបស់ខ្លួនខ្ញុំ ដែលមកពីក្រឹត្យវិន័យនោះទេ គឺជាសេចក្តីសុចរិតដែលមកពីព្រះ ដោយសេចក្តីជំនឿវិញ» (ភីលីព ៣:៨-៩)។ សាវ័ក ប៉ុល បានមើលឃើញថាសេចក្តីសុចរិតរបស់ព្រះគ្រីស្ទដូចជាសម្លៀកបំពាក់ដែលយើងពាក់ដែរ។ យើងព្យាយាមស្លៀកពាក់ខ្លួនយើងដោយស្លឹកល្វានៃសេចក្តីសុចរិតរបស់យើងខ្លួនឯងនៅចំពោះព្រះជាម្ចាស់ ប៉ុន្តែផ្ទុយទៅវិញព្រះអង្គបានស្លៀកពាក់ឲ្យយើងដោយនូវសេចក្តីសុចរិតរបស់ព្រះគ្រីស្ទយ៉ាងសុភាពរាបសារ និងសមរម្យ។ ដូច្នេះ យើងចូលមកចំពោះព្រះវរបិតារបស់យើងដោយប្រដាប់កាយដោយព្រះគ្រីស្ទ។

អ្នកកំណែទម្រង់ជនជាតិបារាំងម្នាក់ឈ្មោះលោក ចន ខិលវិន បានប្រើសាច់រឿងរបស់លោក យ៉ាកុប ដើម្បីបង្ហាញពីរបៀបដែលការនេះដំណើរការ៖

> «លោក យ៉ាកុប មិនសមនឹងទទួលបានសិទ្ធិជាកូនច្បងដោយខ្លួនឯងទេ។ គាត់បានបន្លំខ្លួនធ្វើជាបងប្រុសរបស់គាត់ ដោយស្លៀកសម្លៀកបំពាក់របស់បងប្រុសរបស់គាត់ ដែលមានក្លិនដូចលោក អេសាវ [លោកុប្បត្តិ ២៧:២៧]។ ដោយសារតែការធ្វើដូច្នេះនោះលោក យ៉ាកុប ក៏បានធ្វើឲ្យឪពុករបស់គាត់គាប់ចិត្ត ហើយបានទទួលពរដែលបានបម្រុងទុកសម្រាប់បងប្រុសរបស់គាត់។ ស្រដៀងគ្នានេះដែរ យើងលាក់ខ្លួននៅក្រោមសេចក្តីល្អដ៏បរិសុទ្ធរបស់បងច្បងរបស់យើង គឺអង្គព្រះគ្រីស្ទ។ តាមវិធីនេះ ព្រះជាម្ចាស់អាចទតឃើញយើងថាជាមនុស្សសុចរិតបាន។ …នេះក៏ជាសេចក្តីពិតសម្រាប់យើងផងដែរ ដើម្បីបង្ហាញខ្លួននៅចំពោះព្រះភក្ត្រព្រះជាម្ចាស់សម្រាប់ឲ្យទទួលបានសេចក្តីសង្គ្រោះ នោះយើងត្រូវតែមានការគ្របដណ្តប់ដោយក្លិនក្រអូបរបស់ព្រះគ្រីស្ទ។ ទម្លាប់អាក្រក់របស់យើងត្រូវតែគ្របដណ្តប់ដោយភាពល្អឥតខ្ចោះរបស់ទ្រង់ និងកប់នៅក្រោមភាពល្អឥតខ្ចោះរបស់ទ្រង់»។

លោក ចន ខិលវិន បានកត់សម្គាល់ឃើញប្រធានបទមួយដែលវិលត្រឡប់ទៅឯសួនច្បារអេដែនវិញ។ លោក អ័ដាម និងនាង អេវ៉ា បានយកស្លឹកល្វាមកធ្វើប្រដាប់សម្រាប់បិទបាំងខ្លួន (លោកុប្បត្តិ ៣:៧) ប៉ុន្តែព្រះជាម្ចាស់បានស្លៀកពាក់ពួកគេដោយស្បែកសត្វដែលជាយញ្ញបូជាដំបូងជំនួសវិញ (លោកុប្បត្តិ ៣:២១)។ ដូចគ្នាដែរ យើងក៏មិនចាំបាច់ព្យាយាមស្លៀកពាក់ខ្លួនយើងដោយការខំប្រឹងដោយខ្លួនឯង ដើម្បីប្រឈមមុខនឹងព្រះជាម្ចាស់នោះទេ៖ យើងអាចចូលមកនៅចំពោះព្រះជាម្ចាស់ដោយស្លៀកពាក់ឲ្យបានសមស្រប និងពេញលេញជាមួយនឹងសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ។ ការទទួលបានការរាប់ជាសុចរិតមានន័យថាជាការចូលមកនៅចំពោះព្រះដ៏ជាព្រះវរបិតា មិនមែនក្នុងនាមជាមនុស្សសុចរិតដោយខ្លួនឯងនោះទេ ប៉ុន្តែជាម្នាក់ដែលបានស្លៀកពាក់ជាមួយនឹងសេចក្តីសុចរិតរបស់បងច្បងដ៏សុចរិត និងឥតខ្ចោះរបស់ខ្ញុំ។

មានមនុស្សមួយចំនួនមិនយល់ស្របនឹងគំនិតនេះទេ។ ពួកគេលើកឡើងថា យើងមិនអាចផ្ទេរសេចក្តីសុចរិតពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏គ្រីស្ទបរិស័ទមិនជឿថាព្រះយេស៊ូវបញ្ជូនសេចក្តីសុចរិតរបស់ទ្រង់មកយើងតាមរយៈលំហ

និងពេលវេលានោះទេ។ ផ្ទុយទៅវិញ ព្រះគ្រីស្ទបានគ្រប ដណ្ដប់លើយើងដោយសេចក្ដីសុចរិតរបស់ទ្រង់ ពីព្រោះ យើងពិតជានៅក្នុងទ្រង់។ ដូចដែលលោក ខិលវិន បាន និយាយថា៖

> «យើងមិនមើលទៅព្រះគ្រីស្ទថា ដាច់ចេញពីខ្លួនយើង នោះទេ នៅពេលដែលយើងនិយាយអំពីការដាក់ បញ្ចូលសេចក្ដីសុចរិតរបស់ទ្រង់ក្នុងយើង។ ផ្ទុយទៅ វិញ សេចក្ដីសុចរិតរបស់ទ្រង់ត្រូវបានដាក់បញ្ចូលក្នុង យើង ដោយព្រោះយើងនៅជាប់នឹងព្រះគ្រីស្ទ ហើយ បានជាប់ជាមួយនឹងរូបកាយរបស់ទ្រង់។ នេះគឺដោយ សារតែទ្រង់ស្ម័គ្រព្រះទ័យធ្វើឲ្យយើងរួមមកតែមួយជា មួយនឹងទ្រង់។»

ការនេះគឺល្អជាងគំនិតដ៏សាមញ្ញដែលថា ការរាប់ជា សុចរិតមានន័យថា ពេលព្រះជាម្ចាស់ទតឃើញខ្ញុំ គឺទ្រង់ ឃើញខ្ញុំ «ដូចជាខ្ញុំមិនដែលប្រព្រឹត្តអំពើបាបសោះ»។ ការលេងពាក្យដូចនេះហាក់បីដូចជាវៃឆ្លាតនៅពេលមើល ដំបូង។ នៅពេលដែលខ្ញុំដាក់ទំនុកចិត្តលើព្រះគ្រីស្ទ ខ្ញុំ ពិតជាអរព្រះគុណដល់ព្រះជាម្ចាស់យ៉ាងខ្លាំងព្រោះទ្រង់ បានអត់ទោស និងលាងសម្អាតខ្ញុំទាំងស្រុង។

ប៉ុន្តែ ទោះបីជាខ្ញុំទទួលបានការអត់ទោសក៏ដោយ ក៏ខ្ញុំមិនបានឈប់ធ្វើខុសនោះដែរ។ កំណត់ត្រាដ៏ស្អាតស្អំរបស់ខ្ញុំកំពុងតែរញ៉េរញ៉ៃទៅៗហើយ។ ចុះឥឡូវនេះយ៉ាងម៉េចវិញ? តើខ្ញុំត្រូវការឲ្យព្រះជាម្ចាស់រាប់ខ្ញុំជាសុចរិតម្តងទៀតមែនឬ?

គំនិតនៃ «ការរាប់ជាសុចរិតឡើងវិញ» (re-justification) បង្ហាញថា ខ្ញុំមិនទាន់ទទួលយកអត្តសញ្ញាណថ្មីរបស់ខ្ញុំនៅក្នុងព្រះគ្រីស្ទដ៏ជាសុចរិតទាំងស្រុងនៅឡើយទេ។ សេចក្តីសុចរិតរបស់ខ្ញុំមិនបាន ហើយក៏មិនពឹងផ្អែកលើអាកប្បកិរិយា អារម្មណ៍ ឬភាពស្មោះត្រង់របស់ខ្ញុំឡើយ។ ផ្ទុយទៅវិញ ព្រះគ្រីស្ទគឺជាសេចក្តីសុចរិតរបស់ខ្ញុំ (១កូរិនថូស ១:៣០)។ ព្រះអង្គគឺជាឋានៈ និងជំហររបស់ខ្ញុំនៅចំពោះព្រះជាម្ចាស់–ហើយព្រះអង្គនៅតែដដែល ទាំងម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតតទៅ (ហេព្រើរ ១៣:៨)។ អំពើបាបបច្ចុប្បន្នរបស់ខ្ញុំអាច ហើយក៏នឹងកាត់បន្ថយអំណររបស់ខ្ញុំក្នុងជីវិតជាគ្រីស្ទបរិស័ទមែន ប៉ុន្តែវាមិនអាចផ្លាស់ប្តូរអត្តសញ្ញាណរបស់ខ្ញុំនៅក្នុងទ្រង់បានទេ។

នេះគឺជាការធូរស្រាលដ៏អស្ចារ្យមួយពីការសង្កត់ធ្ងន់របស់សង្គមលើការមានទំនុកចិត្តលើខ្លួនឯង។ ជាការពិតណាស់ ការមានទំនុកចិត្តលើខ្លួនឯង ពេលស្តាប់ទៅធ្វើ

ឲ្យយើងមានអារម្មណ៍អស្ចារ្យណាស់ ពីព្រោះវាធ្វើឲ្យយើងមានអំនួត។ ប៉ុន្តែ វាអាចធ្វើឲ្យអារម្មណ៍របស់លោកអ្នកឡើងចុះៗដូចទឹករលក ប្រសិនបើលោកអ្នកគិតថាលោកអ្នកត្រូវការមានទំនុកចិត្តលើខ្លួនឯងនៅចំពោះព្រះជាម្ចាស់នោះ។

នៅថ្ងៃណាមួយ លោកអ្នកនឹងមានអារម្មណ៍ល្អដោយព្រោះលោកអ្នកបានអធិស្ឋាន តែនៅថ្ងៃបន្ទាប់លោកអ្នកបែរជាមានអារម្មណ៍មិនល្អ ដោយព្រោះលោកអ្នកមិនបានអធិស្ឋាន។ លោកអ្នកមានអារម្មណ៍ស្ងប់ល្អនៅថ្ងៃអាទិត្យ ប៉ុន្តែមានអារម្មណ៍វេទនានៅថ្ងៃច័ន្ទ ដោយព្រោះលោកអ្នកគិតថាព្រះជាម្ចាស់ចូលចិត្ត ឬក៏មិនចូលចិត្តលោកអ្នកដោយផ្អែកលើសកម្មភាព ឬអារម្មណ៍របស់លោកអ្នក។ «កាលនោះព្រះអង្គស្រឡាញ់ខ្ញុំ ប៉ុន្តែឥឡូវនេះព្រះអង្គមិនស្រឡាញ់ខ្ញុំទៀតទេ»។ នេះជាបញ្ហានៅពេលដែលយើងពឹងផ្អែកលើទំនុកចិត្តរបស់យើងលើខ្លួនឯង។

អ្នកជឿមិនមែនសុចរិតដោយសារតែភាពបរិសុទ្ធរបស់ពួកគេខ្លួនឯងនោះទេ។ ព្រះយេស៊ូវមានបន្ទូលថា៖ «ដោយព្រោះខ្ញុំរស់ នោះអ្នករាល់គ្នានឹងរស់ដែរ» (យ៉ូហាន ១៤:១៩)។ ប្រសិនបើខ្ញុំជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទ នោះសេចក្ដីសុចរិត និងព្រះជន្មរបស់ទ្រង់គឺ

ជារបស់ខ្ញុំដែរ។ ដូច្នេះ គ្រីស្ទបរិស័ទទាំងអស់ (មិនថាខ្សោយប៉ុណ្ណានោះទេ) គឺអាចស្រែកប្រកាសពាក្យពេចន៍ដ៏លើកទឹកចិត្តរបស់លោក ឆាលស៍ វេសលី (Charles Wesley) ដោយមានទំនុកចិត្តបានថា៖

*«ឥឡូវនេះ ខ្ញុំមិនខ្លាចការថ្កោលទោសណាមួយឡើយ*
*ដ្បិតព្រះយេស៊ូវ និងអ្វីៗទាំងអស់នៅក្នុងទ្រង់ ជារបស់ខ្ញុំ*
*ខ្ញុំមានជីវិតរស់ក្នុងទ្រង់ ដែលព្រះអង្គជាអ្នកដឹកនាំដ៏មានព្រះជន្មរស់របស់ខ្ញុំ*
*ហើយដោយប្រដាប់ខ្លួនជាមួយនឹងសេចក្តីសុចរិតរបស់ព្រះ*
*នោះខ្ញុំចូលទៅជិតបល្ល័ង្កដ៏អស់កល្បជានិច្ចដោយក្លាហាន*
*ហើយទទួលយកមកុដដែលជារបស់ខ្ញុំតាមរយៈព្រះគ្រីស្ទ»។*

ពេលខ្ញុំបានលុតជង្គង់ចុះនៅចំពោះព្រះជាម្ចាស់ជាលើកដំបូងក្នុងជីវិតរបស់ខ្ញុំ កាលនោះខ្ញុំពិតជាមិនដឹងថានឹងរកពាក្យអ្វីនឹងថ្លែងនោះទេ។ ប៉ុន្តែ ពេលនោះគឺជាលើកដំបូងដែលខ្ញុំបានយល់ថា ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ហើយព្រះអង្គកំពុងរង់ចាំខ្ញុំ។

ខ្ញុំបានស្រែកឡើងថា៖ «ព្រះជាម្ចាស់អើយ! ខ្ញុំគ្មានអ្វីទេ។ ខ្ញុំមិនជាអ្វីសោះឡើយ។ ខ្ញុំមិនចេះអាន ហើយខ្ញុំក៏មិនចេះសរសេរដែរ»។ ភាពអសមត្ថភាពទាំងស្រុងរបស់ខ្ញុំធ្វើឲ្យខ្ញុំពិបាកនិយាយ។ «ឪពុកម្ដាយរបស់ខ្ញុំមិនចង់បានខ្ញុំទេ។ សូមលើកខ្ញុំឡើង ឱព្រះជាម្ចាស់អើយ សូមលើកខ្ញុំឡើង។ ខ្ញុំសុំទោសចំពោះរឿងអាក្រក់ៗទាំង

ឡាយដែលខ្ញុំបានប្រព្រឹត្ត។ ឱព្រះយេស៊ូវអើយ សូមអត់ទោសឲ្យខ្ញុំផង ហើយទទួលយកខ្ញុំឥឡូវនេះ»។

នៅរំពេចនោះ ខ្ញុំមានអារម្មណ៍ថាមានបន្ទុកដ៏ធ្ងន់មួយត្រូវបានលើកចេញពីខ្នងរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ធូរស្រាល និងស្ងប់ចិត្តយ៉ាងខ្លាំង។ ខ្ញុំមានការភ្ញាក់ផ្អើលចំពោះអំណរដែលបានមកបំពេញក្នុងខ្ញុំ។ ខ្ញុំគ្រាន់តែជាក្មេងម្នាក់ដែលត្រូវបានគេបំភ្លេចចោលក្នុងចំណោមមនុស្សរាប់លាននាក់នៅទ្វីបអាហ្វ្រិក ប៉ុន្តែព្រះយេស៊ូវបានរកឃើញខ្ញុំ។ «ខ្ញុំមានអារម្មណ៍ដូចជាមនុស្សថ្មីទាំងស្រុង។ ជីវិតចាស់ និងភាពភ័យខ្លាចរបស់ខ្ញុំទាំងអស់បានរលាយបាត់ទៅហើយ ហើយអ្វីៗទាំងអស់គឺថ្មីសម្រាប់ខ្ញុំ»។ ខ្ញុំបានស្គាល់ព្រះជាម្ចាស់តាមរបៀបមួយដែលខ្ញុំមិនអាចស្រមៃបានកាលពីម្សិលមិញ នៅពេលដែលខ្ញុំកំពុងប្រមូលដប ដើម្បីធ្វើគ្រាប់បែកម៉្យាងផ្សំឡើងដោយសាំង។

Stephen Lungu, with Anne Coomes
*Out of the Black Shadows:*
*The Amazing Transformation of Stephen Lungu*

៤

# ការប្តូរគ្នាដ៏គួរឲ្យភ្ញាក់ផ្អើល

តើស្រីពេស្យាអាចក្លាយជាម្ចាស់ក្សត្រីយ៉ាងដូចម្តេចបាន? ប្រហែលជានៅក្នុងរឿងប្រឌិតទេដឹង–ប៉ុន្តែមិនមែននៅក្នុងជីវិតពិតនោះទេ មែនទេ?

នៅពេលដែលលោក ម៉ធិន លូសើរ ចាប់ផ្តើមពន្យល់អំពីដំណឹងល្អនៃសេចក្តីសុចរិតដែលគាត់បានឃើញនៅក្នុងព្រះគម្ពីរ នោះគាត់បានពណ៌នាអំពីផ្ទៃរឿងដ៏ចម្បងមួយនៅក្នុងព្រះគម្ពីរអំពីអាពាហ៍ពិពាហ៍របស់ព្រះគ្រីស្ទទៅនឹងក្រុមជំនុំរបស់ទ្រង់ (អេសាយ ៦១:១០-៦២:៥; វិវរណៈ ១៩:៦-៨)។ ស្តេចមួយអង្គ (ដែលជាអង្គព្រះយេស៊ូវ) បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនារីដ៏ក្រីក្រម្នាក់ ដែលកំពុងជំពាក់បំណុលគេ។ តាមពិតទៅ នារីម្នាក់នេះពិតជាស្រីពេស្យា (ដែលជាយើង)។ បំណុលរបស់នាងច្រើនពេក មិនអាចបង់សងអស់បានឡើយ ហើយនាងក៏មិនអាចខំប្រឹងធ្វើការឲ្យបានគ្រប់គ្រាន់ល្មម ដើម្បីក្លាយជាម្ចាស់ក្សត្រីម្នាក់បាន

ដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ស្ដេចនោះស្រឡាញ់នាង ហើយទ្រង់បានព្យាយាមយកឈ្នះចិត្តនាង។ នៅថ្ងៃអាពាហ៍ពិពាហ៍របស់ពួកគេ នាងបាននិយាយទៅកាន់ព្រះអង្គថា៖ «អ្វីៗទាំងអស់ដែលជាខ្ញុំម្ចាស់ នោះខ្ញុំម្ចាស់ថ្វាយដាច់ដល់ព្រះអង្គហើយ ហើយអ្វីៗទាំងអស់ដែលខ្ញុំម្ចាស់មាន នោះខ្ញុំម្ចាស់ក៏ចែករំលែកជាមួយនឹងទ្រង់ដែរ!»។ ដោយការនិយាយដូច្នេះ នាងបានថ្វាយបំណុល និងភាពអាម៉ាស់ទាំងអស់របស់នាងទៅទ្រង់។

បន្ទាប់មក ព្រះមហាក្សត្របានមានបន្ទូលទៅកាន់នាងថា៖ «អ្វីៗទាំងអស់ដែលជាយើង នោះយើងថ្វាយដាច់ដល់អូនហើយ ហើយអ្វីៗទាំងអស់ដែលយើងមាន នោះយើងក៏ចែករំលែកជាមួយនឹងអូនដែរ»។ ដោយមានបន្ទូលទាំងនេះ នោះព្រះអង្គបានក្លាយជារបស់នាង ហើយនាងបានទទួលទ្រព្យសម្បត្តិ និងនគរទាំងអស់របស់ទ្រង់។

ដោយបន្ទូលតែមួយព្រះឱស្ឋ នោះស្រីពេស្យានោះក៏បានក្លាយជាម្ចាស់ក្សត្រី។

ឧទាហរណ៍នេះបង្ហាញអំពីការប្ដូរគ្នាទៅវិញទៅមកនៅក្នុងអាពាហ៍ពិពាហ៍ដ៏អស្ចារ្យ និងដ៏រីករាយដែលនេះជាដំណឹងល្អ។ ព្រះគ្រីស្ទដែលជាកូនកំលោះដ៏អស្ចារ្យរបស់យើង បានទទួលយកអំពើបាប សេចក្ដី

ស្លាប់ និងការជំនុំជម្រះរបស់យើងទាំងអស់។ ព្រះអង្គបានផ្ទុកវានៅលើឈើឆ្កាង ហើយទ្រង់បានជ្រមុជវានៅក្នុងព្រះលោហិតរបស់ទ្រង់។ បន្ទាប់មក ព្រះអង្គបានប្រទានដល់យើងនូវសេចក្ដីសុចរិត ព្រះពរ និងឋានៈដ៏ស្ងួនភ្ងាទាំងអស់របស់ទ្រង់នៅចំពោះព្រះវរបិតារបស់ទ្រង់។ លោក ម៉ធិន បានលើកឡើងថាដោយសារតែការនេះ នោះមនុស្សមានបាបអាចបង្ហាញដោយទំនុកចិត្តអំពី «អំពើបាបរបស់ខ្លួននៅចំពោះមុខសេចក្ដីស្លាប់និងស្ថាននរក ហើយអាចនិយាយបានថា "ប្រសិនបើខ្ញុំបានប្រព្រឹត្តអំពើបាប៖ តែខ្ញុំជឿលើព្រះគ្រីស្ទ ដែលទ្រង់មិនធ្លាប់ប្រព្រឹត្តអំពើបាបសោះ"»។ អ្វីៗទាំងអស់ដែលជារបស់ទ្រង់ ឥឡូវនេះគឺជារបស់ខ្ញុំ ហើយអ្វីៗទាំងអស់ដែលជារបស់ខ្ញុំ ឥឡូវនេះគឺជារបស់ទ្រង់ដែរ»។

រឿងនេះកែតម្រូវការយល់ច្រឡំថា ឥឡូវនេះ ជំនឿជាកិច្ចការតែមួយគត់ដែលយើងត្រូវតែ «នឹងខំប្រឹងធ្វើ» ដើម្បីបានសេចក្ដីសង្គ្រោះ។ ប្រសិនបើនេះជាការពិត នោះយើងនឹងផ្ដោតសម្លឹងមើលមកខ្លួនឯងដោយឆ្ងល់ថា តើយើងកំពុង «ប្រតិបត្តិ» ជំនឿគ្រប់គ្រាន់ល្មមឬក៏អត់ជាមិនខាន។ វាអាចមានប្រយោជន៍ក្នុងការពណ៌នាអំពីការប្ដូរគ្នានេះថាជា «ការរាប់ជាសុចរិតដោយសារព្រះបន្ទូលនៃព្រះ» ជំនួសឲ្យ «ការរាប់ជា

សុចរិតដោយសារជំនឿ» ពីព្រោះគឺជាព្រះបន្ទូលរបស់ព្រះទេដែលរាប់យើងជាសុចរិតនៅត្រង់នេះ មិនមែនជំនឿរបស់យើងរាប់យើងជាសុចរិតដោយខ្លួនឯងនោះទេ។ យើងមិនចាំបាច់សួរថា «តើខ្ញុំមានជំនឿល្មមគ្រប់គ្រាន់ឬទេ?» នោះទេ។ ជំនឿគឺគ្រាន់តែទទួលស្គាល់ ទទួលយក និងទទួលជឿលើព្រះគ្រីស្ទ–ហើយមានព្រះអង្គគឺគ្រប់គ្រាន់ហើយ។

នៅពេលដែលយើងសង្ស័យអំពីទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ នោះយើងមិនគួរមើលខាងក្នុងខ្លួនយើង ដើម្បីពិនិត្យថាតើយើងសុចរិតប៉ុណ្ណានោះទេ។ សេចក្តីសុចរិតរបស់យើងគឺនៅខាងក្រៅយើង វាដូចជាសម្លៀកបំពាក់អញ្ជឹងដែរ។ នៅពេលដែលកូនកំលោះស្បថសច្ចាក្នុងថ្ងៃអាពាហ៍ពិពាហ៍ នោះឋានៈរបស់ស្រីពេស្យាបានផ្លាស់ប្តូរ ហើយនាងបានក្លាយជាម្ចាស់ក្សត្រី។ ការផ្លាស់ប្តូរឋានៈនេះមិនមែនមកពីការផ្លាស់ប្តូរពីខាងក្នុងទៅលើអត្តចរិតរបស់នាងនោះទេ។ នាងមិនបានក្លាយជាម្ចាស់ក្សត្រី បន្ទាប់ពីនាងចាប់ផ្តើមប្រព្រឹត្តដូចជាម្ចាស់ក្សត្រីនោះទេ។

ចំពោះអ្នកជឿ គឺដូចនេះ៖ នាងនឹងកាន់តែដូចព្រះគ្រីស្ទទៅតាមពេលវេលា ប៉ុន្តែនាងនឹងមិនកាន់តែសុចរិតនោះទេ។ ដោយសារតែសេចក្តីប្រកាស

របស់ព្រះជាម្ចាស់ នោះនាងទទួលបានឋានៈដ៏សុចរិត ដែលឋានៈនេះគឺជាកម្មសិទ្ធិរបស់ព្រះគ្រីស្ទ។ វាមិនមែន ដោយសារតែការធ្វើខ្លួនឯងឲ្យប្រសើរឡើង ដោយខ្លួនឯងនោះទេ។ នាងនៅតែជាមនុស្សមានបាប ហើយបន្តធ្វើខុស និងដើរខុសផ្លូវ ប៉ុន្តែនាងមានឋានៈដ៏សុចរិតរបស់កូនកំលោះដ៏ល្អឥតខ្ចោះ និងជាស្តេចរបស់នាង។ នាងមានទាំងបាប និងសេចក្តីសុចរិតក្នុងពេលតែមួយ –ពោលគឺមានបាបនៅក្នុងខ្លួននាង ប៉ុន្តែមានសេចក្តីសុចរិតដ៏ល្អឥតខ្ចោះនៅក្នុងឋានៈរបស់នាង ដោយសារតែសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ។ ពួកយើងដែលទុកចិត្តលើព្រះគ្រីស្ទមិនអាចទទួលការថ្កោលទោសចំពោះអំពើបាបទាំងប៉ុន្មានដែលនៅតែមាននៅក្នុងចិត្ត និងជីវិតរបស់យើងបានទេ ហើយមធ្យោបាយតែមួយគត់ដែលពួកយើងអាចទទួលការថ្កោលទោស គឺប្រសិនបើព្រះគ្រីស្ទអង្គទ្រង់ផ្ទាល់ត្រូវទទួលការថ្កោលទោសជាមួយនឹងពួកយើងដែរ។ អ្វីៗទាំងអស់ដែលជារបស់ទ្រង់គឺជារបស់យើងដែរ។

លោកគ្រូអធិប្បាយម្នាក់ឈ្មោះ រីឆាត ស៊ីបស៍ (Richard Sibbes) បានសរសេរយ៉ាងដូច្នេះថា៖

> «សូមគិតអំពីការនេះជាមួយនឹងខ្លួនឯងថា “តើខ្ញុំជាអ្វី?” ខ្ញុំជាមនុស្សក្រីក្រ ហើយមានបាប។ ប៉ុន្តែ ខ្ញុំមាន

សេចក្ដីសុចរិតនៅក្នុងព្រះគ្រីស្ទដែលដោះស្រាយអ្វីៗគ្រប់យ៉ាង។ ខ្ញុំខ្សោយដោយកម្លាំងខ្លួនឯង ប៉ុន្តែព្រះគ្រីស្ទទ្រង់រឹងមាំ ដូច្នេះខ្ញុំរឹងមាំនៅក្នុងទ្រង់។ ខ្ញុំល្ងង់ខ្លៅដោយខ្លួនឯង ប៉ុន្តែខ្ញុំមានប្រាជ្ញាដោយសារទ្រង់។ អ្វីដែលខ្ញុំខ្វះខាតនៅក្នុងខ្លួនខ្ញុំ នោះខ្ញុំមាននៅក្នុងទ្រង់។ ព្រះអង្គជារបស់ខ្ញុំ ហើយសេចក្ដីសុចរិតរបស់ទ្រង់ក៏ជារបស់ខ្ញុំ ដែលនោះជាសេចក្ដីសុចរិតរបស់ព្រះ ១០០% និងមនុស្ស ១០០% ។ ដោយបំពាក់សេចក្ដីសុចរិតនោះ ខ្ញុំមានសុវត្ថិភាពទាស់នឹងពិរុទ្ធភាព ស្ថាននរក ការជំនុំជម្រះ និងអ្វីៗផ្សេងទៀត។ ទោះបីជាខ្ញុំតយុទ្ធនឹងអំពើបាបរបស់ខ្ញុំជារៀងរាល់ថ្ងៃក៏ដោយ ក៏ខ្ញុំនៅតែជារបស់ផងព្រះគ្រីស្ទ។ សេចក្ដីសុចរិតរបស់ទ្រង់ធំជាងអំពើបាបទាំងប៉ុន្មានដែលមាននៅក្នុងខ្ញុំទៅទៀត»។

យើងរឹងមាំនៅក្នុងទ្រង់ មានប្រាជ្ញានៅក្នុងទ្រង់ ហើយមានសុវត្ថិភាពនៅក្នុងទ្រង់។

«ច្រវាក់របស់ខ្ញុំបានរបូតចេញ»។

ស្នាដៃអក្សរសាស្រ្តបុរាណដ៏សំខាន់មួយរបស់គ្រីស្ទបរិស័ទគឺសៀវភៅដែលមានចំណងជើងថា «ផ្លូវស្ថានសួគ៌» (Pilgrim's Progress) របស់លោក ចន ប៊ុនយ៉ាន (John Bunyan)។

លោក ចន ប៊ុនយ៉ាន ធ្លាប់ធ្វើការជាអ្នកជួសជុលសម្ភារៈផ្ទះបាយ។ គាត់បានធ្វើដំណើរពីភូមិមួយទៅភូមិមួយ ដោយស្ពាយដែកទ្រនាប់ទម្ងន់ ២៧ គីឡូក្រាម និងឧបករណ៍ជួសជុលដ៏ធ្ងន់នៅលើស្មារបស់គាត់។ នៅក្នុងសៀវភៅរឿង «ផ្លូវស្ថានសួគ៌» នោះ សម្ពាយនេះបានក្លាយជាគំរូសម្រាប់បន្ទុកនៃពិរុទ្ធភាពដ៏ធំដែលអ្នកធ្វើដំណើរទៅជួបព្រះបានស្ពាយនៅលើស្មារបស់គាត់។ បន្ទុកនេះនៅជាមួយនឹងអ្នកធ្វើដំណើរទៅជួបព្រះនោះរហូតដល់គាត់មកដល់ឈើឆ្កាង ហើយបន្ទុកនោះត្រូវបាន «ដកចេញពីស្មារបស់គាត់» ដែលការនោះបានធ្វើឲ្យគាត់មានការធូរស្រាលយ៉ាងខ្លាំង។

កាលពីនៅក្មេង លោក ចន ប៊ុនយ៉ាន គឺស្រដៀងគ្នានឹងលោក ម៉ាធិន លូសើរ ខ្លាំងណាស់ ពីព្រោះគាត់មានអារម្មណ៍ថាអស់សង្ឃឹមដោយសារតែពិរុទ្ធភាពរបស់គាត់។ គាត់ខ្លាចថា «ព្រះគ្រីស្ទនឹងមិនអត់ទោស

ឲ្យខ្ញុំទេ»។ រហូតដល់គាត់បានឃើញដូចគ្នានឹងអ្វីដែល លោក ម៉ធិន លូសើរ បានឃើញដែរ៖

«ប៉ុន្តែថ្ងៃមួយ ពេលខ្ញុំដើរតាមវាលស្រែ នោះខ្ញុំមាន អារម្មណ៍ថា អ្វីៗគ្រប់យ៉ាងមិនត្រឹមត្រូវទេ ពីព្រោះខ្ញុំ មានពិរុទ្ធនៅក្នុងសតិសម្បជញ្ញៈរបស់ខ្ញុំ។ រំពេចនោះ ប្រយោគនេះបានចូលមកដល់ចិត្តគំនិតរបស់ខ្ញុំថា៖ «សេចក្តីសុចរិតរបស់អ្នកគឺនៅឯស្ថានសួគ៌»។ ហើយ ខ្ញុំបានឃើញ ព្រះយេស៊ូវគ្រីស្ទគង់នៅខាងស្តាំព្រះហស្ត របស់ព្រះជាម្ចាស់ ដោយភ្នែកនៃព្រលឹងរបស់ខ្ញុំ។ ខ្ញុំ បានដឹងថាមានសេចក្តីសុចរិតរបស់ខ្ញុំនៅទីនោះ។ ដូច្នេះ មិនថាខ្ញុំនៅកន្លែងណា ឬខ្ញុំកំពុងធ្វើអ្វីក៏ដោយ ក៏ព្រះជាម្ចាស់អាចមានបន្ទូលអំពីខ្ញុំថា «គាត់មាន សេចក្តីសុចរិតរបស់ព្រះ» ដោយព្រោះព្រះគ្រីស្ទតែង តែគង់នៅទីនោះនៅចំពោះទ្រង់ជានិច្ច»។

លោក ចន ប៊ុនយ៉ាន យល់ថាវាមិនសំខាន់ទេដែល គាត់មានអារម្មណ៍ល្អចំពោះខ្លួនឯង ឬក៏អត់នោះទេ។ មិន ថាមានអារម្មណ៍ល្អ ឬមានអារម្មណ៍មិនល្អ។

សេចក្តីសុចរិតរបស់ខ្ញុំគឺព្រះយេស៊ូវគ្រីស្ទផ្ទាល់។ ព្រះ អង្គនៅដដែលទាំងម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត តទៅ។ ឥឡូវនេះ ច្រវាក់របស់ខ្ញុំពិតជាបានរបូតចេញ

ពីជើងរបស់ខ្ញុំមែនហើយ។ ខ្ញុំបានរួចពីទុក្ខវេទនា និង ចំណងរបស់ខ្ញុំហើយ។ ពេលនោះ ខ្ញុំក៏បានត្រឡប់ ទៅផ្ទះវិញដោយមានអំណរ ដោយសារព្រះគុណ និង សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

៥

# មែនហើយ ប៉ុន្តែ...តើយើងពន្យល់ពីការប្រព្រឹត្ត និងជំនឿយ៉ាងដូចម្តេច?

ចូរយើងគិតអំពីអំណះអំណាងមួយចំនួន ដែលអាចដកអំណរខ្លះចេញពីដំណឹងល្អនេះ។ អំណះអំណាងទីមួយគឺចេញពីព្រះគម្ពីរ នៅក្នុងសំបុត្ររបស់លោក យ៉ាកុប ២:១៤-២៥៖

«បងប្អូនអើយ បើអ្នកណាថាខ្លួនមានសេចក្តីជំនឿ តែមិនប្រព្រឹត្តតាម នោះតើមានប្រយោជន៍អ្វី តើសេចក្តីជំនឿអាចនឹងជួយសង្គ្រោះអ្នកនោះបានដែរឬ ចុះបើមានបងប្អូនប្រុសស្រីណានៅអាក្រាត ព្រមទាំងខ្វះអាហារបរិភោគរាល់តែថ្ងៃ ហើយអ្នករាល់គ្នាណាមួយនិយាយទៅអ្នកនោះថា អញ្ជើញទៅឲ្យសុខសាន្តសូមឲ្យបានកក់ក្តៅ ហើយឆ្អែតចុះ តែគ្មានឲ្យអ្វីដល់អ្នកដែលត្រូវការខាងរូបសាច់នោះសោះ នោះតើមាន

ប្រយោជន៍អ្វី ឯសេចក្ដីជំនឿក៏បែបដូច្នោះដែរ បើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង តែអ្នកខ្លះនឹងនិយាយថា អ្នកមានសេចក្ដីជំនឿ ហើយខ្ញុំមានការប្រព្រឹត្ត ដូច្នេះ ចូរអ្នកបង្ហាញសេចក្ដីជំនឿរបស់អ្នកក្រៅពីការដែលអ្នកប្រព្រឹត្តឲ្យខ្ញុំឃើញផង នោះខ្ញុំនឹងបង្ហាញសេចក្ដីជំនឿខ្ញុំ ដោយសារការដែលខ្ញុំប្រព្រឹត្តដែរ អ្នកជឿថា មានព្រះតែ១ នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ ឱមនុស្សកំឡៅអើយ អ្នកចង់ដឹងពិតឬទេថា សេចក្ដីជំនឿដែលឥតមានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ? ចុះលោកអ័ប្រាហាំ ជាពួយុកោយើង តើមិនបានរាប់ជាសុចរិត ដោយការលោកប្រព្រឹត្ត ក្នុងកាលដែលលោកបានថ្វាយអ៊ីសាក ជាកូនលោក នៅលើអាសនាទេឬអី ដូច្នេះ អ្នកឃើញថា សេចក្ដីជំនឿបានរួមជាមួយនឹងការដែលលោកប្រព្រឹត្ត ហើយសេចក្ដីជំនឿបានគ្រប់លក្ខណ៍ ដោយសារការនោះឯង នោះទើបបានសំរេចបទគម្ពីរ ដែលថា «អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្ដីនោះ បានរាប់ជាសេចក្ដីសុចរិតដល់លោក» ព្រះក៏ហៅលោកជាសំឡាញ់របស់ទ្រង់ដែរ ដូច្នេះ អ្នករាល់គ្នាឃើញថា មនុស្សបានរាប់ជាសុចរិត មិនមែនដោយសារតែសេចក្ដីជំនឿប៉ុណ្ណោះទេ គឺដោយសារការប្រព្រឹត្តដែរ ឯនាងរ៉ាហាប ជាស្រីសំផឹង ក៏ដូច្នោះដែរ តើនាងមិនបានរាប់ជាសុចរិត ដោយសារការនាងប្រព្រឹត្តទេឬអី គឺក្នុងកាលដែលនាងទទួលពួក

> អ្នក ដែលគេចាត់មកនោះ ហើយនាងបានឲ្យគេចេញទៅវិញតាមផ្លូវ១ទៀត ពីព្រោះសេចក្ដីជំនឿ បើគ្មានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ ប្រៀបដូចជារូបកាយ បើឥតមានព្រលឹងវិញ្ញាណទេ នោះក៏ស្លាប់ហើយដែរ» (យ៉ាកុប ២:១៤-២៦)។

នៅពេលមើលមួយភ្លែត វាហាក់ដូចជាលោក យ៉ាកុប កំពុងតែនិយាយអំពីអ្វីមួយដែលខុសគ្នាខ្លាំងពីអ្វីដែលសាវ័ក ប៉ុល បង្រៀន! ប៉ុន្តែ ពេលយើងពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ទៅលើអំណះអំណាងរបស់លោក យ៉ាកុប នោះភាពខុសគ្នានឹងរលាយបាត់ទៅវិញជាមិនខាន។

លោក យ៉ាកុប កំពុងគិតអំពីព្រឹត្តិការណ៍ពីរយ៉ាងចេញពីជីវិតរបស់លោក អ័ប្រាហាំ។ ព្រឹត្តិការណ៍ទីមួយគឺនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក១៥ និងព្រឹត្តិការណ៍ទីពីរគឺនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក២២។ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ១៥:៦ បានចែងថា៖ «គាត់ [លោក អ័ប្រាហាំ] ក៏ជឿដល់ព្រះយេហូវ៉ា ហើយទ្រង់រាប់សេចក្ដីជំនឿនោះ ទុកជាសេចក្ដីសុចរិតដល់គាត់»។ នេះជាខគម្ពីរដូចគ្នាដែលសាវ័ក ប៉ុល បានប្រើនៅក្នុងកណ្ឌគម្ពីរ រ៉ូម ជំពូក៤ ដើម្បីបង្ហាញថា យើងបានទទួលការរាប់ជាសុចរិតដោយសារជំនឿតែមួយមុខ។ បន្ទាប់មក នៅ

ក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក២២ បន្ទាប់ពីគាត់ទទួលបានការរាប់ជាសុចរិតជាច្រើនឆ្នាំ នោះលោក អ័ប្រាហាំ បានគោរពតាមសេចក្ដីបង្គាប់របស់ព្រះជាម្ចាស់ ឲ្យថ្វាយកូនប្រុសរបស់គាត់ឈ្មោះ អ៊ីសាក ជាយញ្ញបូជានៅលើអាសនា (សូមអាន ខ.២១ ខាងលើ)។

នេះជាគោលបំណងរបស់លោក យ៉ាកុប ក្នុងការរំលេចឡើងនូវអត្ថបទព្រះគម្ពីរទាំងពីរនេះ៖ លោក អ័ប្រាហាំទទួលបានការរាប់ជាសុចរិតរួចទៅហើយនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក១៥ ហើយការប្រព្រឹត្តរបស់គាត់នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក២២ ក៏បង្ហាញអំពីសេចក្ដីសុចរិតរបស់គាត់ ហើយបានបញ្ជាក់អំពីជំនឿរបស់គាត់ថាជាជំនឿពិត និងជាជំនឿដ៏រស់ផងដែរ។ តាមរបៀបនេះ គាត់ទទួលបានការ «រាប់ជាសុចរិត» ដោយសារការប្រព្រឹត្តរបស់គាត់។ លោក យ៉ាកុប មិនបាននិយាយថា ការរាប់ជាសុចរិតគឺជាដំណើរការនៃការក្លាយជាមនុស្សបរិសុទ្ធ ឬសុចរិតជាងមុននោះទេ។ ការប្រព្រឹត្តរបស់គាត់បង្ហាញថាលោក អ័ប្រាហាំ និងជំនឿរបស់គាត់គឺពិតប្រាកដមែន។ ការប្រព្រឹត្តរបស់លោក អ័ប្រាហាំ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក២២ មិនបានបន្ថែមទៅលើសេចក្ដីសុចរិតដែលគាត់មានរួចហើយនៅក្នុងកណ្ឌ

គម្ពីរ លោកុប្បត្តិ ជំពូក១៥ នោះទេ ប៉ុន្តែគឺជាការប្រព្រឹត្ត ដែលបង្ហាញថា ជំនឿរបស់គាត់គឺជាជំនឿពិត។

នេះជាមធ្យោបាយតែមួយគត់ ដើម្បីឲ្យយល់អំពី អំណះអំណាងរបស់លោក យ៉ាកុប។ លោក យ៉ាកុប បានសរសេរថា «ជំនឿ» ដែលគ្រាន់តែជឿលើសេចក្តី ពិត ប៉ុន្តែមិនមានការប្រព្រឹត្ត (ខ.១៩) គឺជាជំនឿដែល ស្លាប់ ដែលមិនអាចនាំទៅរកសេចក្តីសង្គ្រោះនោះបាន ទេ (ខ.១៧, ២៦)។ ជំនឿដ៏រស់គឺជាការទុកចិត្តដោយ ស្មោះត្រង់លើព្រះគ្រីស្ទ។ ជំនឿនេះនឹងបង្ហាញឲ្យឃើញ តាមរយៈសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់ ជាមួយ នឹងការមានជីវិតដែលបានផ្លាស់ប្រែ និងការប្រព្រឹត្តល្អ –ពោលគឺដូចជំនឿរបស់លោក អ័ប្រាហាំ នៅក្នុងកណ្ឌ គម្ពីរ លោកុប្បត្តិ ជំពូក១៥ ដែរ។ ជំនឿរបស់គាត់បាន បង្ហាញថាជាជំនឿដ៏រស់តាមរយៈការប្រព្រឹត្តរបស់គាត់ នៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក២២។

អ្នកដែលទុកចិត្តលើព្រះអម្ចាស់ដូចដែលលោក អ័ប្រាហាំ បានទុកចិត្តដែរនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ជំពូក១៥ គឺនឹងទទួលបានការរាប់ជាសុចរិតដោយសារ ជំនឿតែមួយគត់។ ទោះជាយ៉ាងណាក៏ដោយ ក៏ជំនឿ ដែលរស់ និងនាំទៅរកសេចក្តីសង្គ្រោះនឹងតែងតែបង្ហាញ ឲ្យឃើញនៅក្នុងការប្រព្រឹត្តល្អ។ មានតែជំនឿមួយមុខ

ទេដែលរាប់ជាសុចរិត ប៉ុន្តែជំនឿដែលរាប់ជាសុចរិតមិន
ដែលនៅតែឯងឡើយ (ខ.២២)។

៦

# មែនហើយ ប៉ុន្តែ...តើយើងនៅបន្តធ្វើបាបទៀតឬ?

បញ្ហាមួយទៀតដែលមនុស្សតែងមានជាមួយនឹងការរាប់ជាសុចរិតគឺថា វាហាក់ដូចជាកាត់បន្ថយការទទួចឲ្យរស់នៅបរិសុទ្ធនៅក្នុងព្រះគម្ពីរ។ ប្រសិនបើយើងចូលចិត្តប្រព្រឹត្តបាប ហើយព្រះជាម្ចាស់សព្វព្រះទ័យអត់ទោសបាបឲ្យយើង នោះហេតុអ្វីបានជាយើងគួររស់នៅក្នុងជីវិតបរិសុទ្ធ ដ្បិតសេចក្ដីសង្គ្រោះគឺជាអំណោយ ហើយមិនមែនជាអ្វីដែលយើងរកបានដោយការប្រព្រឹត្តអំពើល្អនោះទេ? ប្រសិនបើស្ថានសួគ៌ជាអំណោយដោយឥតគិតថ្លៃ តើគ្រីស្ទបរិស័ទគួរ «ចេះតែប្រព្រឹត្តអំពើបាបទៅទៀត ដើម្បីឲ្យព្រះគុណបានចម្រើនឡើងឬអី» (រ៉ូម ៦:១)?

ប៉ុន្តែ នោះមិនមែនជាអ្វីដែលយើងមើលឃើញនៅក្នុងព្រះគម្ពីរនោះទេ។ ព្រះជាម្ចាស់មិនបានប្រទានដល់យើងនូវបំណែកនៃសេចក្ដីសុចរិត ឬសេចក្ដីសង្គ្រោះពី

ស្ថានសួគ៌នោះទេ។ ប្រសិនបើការរាប់ជាសុចរិតដំណើរការតាមវិធីនេះ នោះយើងអាចទទួលយកអំណោយទាននោះ ហើយនៅបន្តប្រព្រឹត្តអំពើបាបទៀតបាន។ ផ្ទុយទៅវិញ ព្រះជាម្ចាស់បានប្រទានដល់យើងនូវព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ ហើយដោយការនៅក្នុងទ្រង់ និងគ្របបាំងដោយទ្រង់ នោះយើងមានសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ។ នោះជាហេតុផលតែមួយគត់ដែលយើងមានសេចក្តីសុចរិតរបស់ទ្រង់គឺដោយព្រោះយើងមានទ្រង់។ លោក ម៉ាធិន លូសើរ បានសរសេរថា «សេចក្តីសុចរិតរបស់ព្រះគ្រីស្ទបានក្លាយជាសេចក្តីសុចរិតរបស់យើងតាមរយៈជំនឿ ហើយអ្វីៗទាំងអស់ដែលទ្រង់មានក៏បានក្លាយជារបស់យើង ហើយតាមពិតទៅព្រះអង្គទ្រង់ផ្ទាល់បានក្លាយជារបស់យើងដែរ»។

សូមគិតអំពីស្រីពេស្យាដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងមហាក្សត្រ។ មែនហើយ នាងទទួលបាននគរ ប៉ុន្តែនាងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងមហាក្សត្រនោះ ដើម្បីរស់នៅជាមួយនឹងទ្រង់។ ដូចគ្នានេះដែរ អ្នកជឿចូលមករកព្រះគ្រីស្ទ ដើម្បីទទួលទ្រង់ មិនមែនដើម្បីទទួលបាននគរស្ថានសួគ៌ សេចក្តីសុចរិត ជីវិត ឬព្រះពរផ្សេងៗទៀតនោះទេ។ ប៉ុន្តែ តាមរយៈការទទួលបានព្រះគ្រីស្ទ ហើយនិងការនៅក្នុងទ្រង់ នោះព្រះ

អង្គក៏បានប្រទានព្រះពរផ្សេងៗទៀតទាំងអស់ដល់យើងផងដែរ។

សូមពិចារណាអំពីសាវ័ក ប៉ុល ដែលបានសរសេរអំពីសេចក្តីសង្គ្រោះ ដោយសារព្រះគុណតែមួយគត់។ នៅពេលលោកសរសេរទៅកាន់ក្រុមជំនុំនៅទីក្រុងភីលីព លោកបានលើកឡើងថា បំណងប្រាថ្នារបស់លោកគឺ «ចេញទៅនៅជាមួយព្រះគ្រីស្ទ» មិនមែន «នៅនគរស្ថានសួគ៌» នោះទេ (ភីលីព ១:២៣)។ ចំពោះលោក ព្រះគ្រីស្ទគឺជាហេតុផលដ៏អស្ចារ្យបំផុត ដើម្បីទៅឯនគរស្ថានសួគ៌។

ដូចជានារីម្នាក់ដែលជំពាក់បំណុលបានរៀនធ្វើដូចជាម្ចាស់ក្សត្រីនៅពេលដែលនាងរស់នៅជាមួយនឹងមហាក្សត្រអញ្ចឹងដែរ នោះអ្នកជឿគ្រប់ៗរូបក៏ទទួលបានការផ្លាស់ប្តូរដោយសារការស្គាល់ និងការរស់នៅជាមួយព្រះគ្រីស្ទផងដែរ។ អ្នកដែលបំពាក់សេចក្តីសុចរិតរបស់ព្រះគ្រីស្ទ គឺបានពេញដោយព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ ជាព្រះវិញ្ញាណដែលធ្វើការបំផ្លាស់បំប្រែ។ លោកអ្នកមិនអាចបំពាក់ដោយសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ ដោយមិនបាននៅរួមជាមួយនឹងព្រះគ្រីស្ទ  ដែលនឹងបំផ្លាស់បំប្រែលោកអ្នកឲ្យកាន់តែដូចទ្រង់បានទេ។ ព្រះអង្គគឺជាសេចក្តីសង្គ្រោះ។ នៅក្នុងទ្រង់មានគ្រប់ទាំងសេចក្តី

សុចរិត ហើយការស្គាល់ទ្រង់គឺជាភាពសំខាន់នៃភាពបរិសុទ្ធ។

បើនិយាយម្យ៉ាងវិញទៀត សេចក្ដីសង្គ្រោះដោយសារព្រះគុណតែមួយមុខមានន័យដូចគ្នានឹងសេចក្ដីសង្គ្រោះដោយសារព្រះគ្រីស្ទតែមួយគត់ដែរ។ បើគ្មានព្រះគ្រីស្ទ នោះក៏នឹងគ្មានព្រះគុណ គ្មានសេចក្ដីសង្គ្រោះ និងគ្មានសេចក្ដីសុចរិតណាដែរ។ ដូច្នេះ ព្រះគុណបំផ្លាស់បំប្រែមនុស្ស ដូចដែលសាវ័ក ប៉ុល បានបង្រៀនថា៖

> «ព្រះគុណនៃព្រះ ដែលនាំសេចក្ដីសង្គ្រោះមកដល់មនុស្សទាំងឡាយ បានលេចមកហើយ ទាំងបង្ហាត់បង្រៀនយើងរាល់គ្នា ឲ្យលះចោលសេចក្ដីទមិលល្មើស នឹងសេចក្ដីប៉ងប្រាថ្នាក្នុងលោកនេះ ហើយឲ្យរស់នៅក្នុងសម័យនេះ ដោយសេចក្ដីធ្ងន់ធ្ងរ សេចក្ដីសុចរិត ហើយដោយគោរពប្រតិបត្តិដល់ព្រះវិញ ទាំងរង់ចាំសេចក្ដីសង្ឃឹមដ៏មានពរ គឺឲ្យបានឃើញដំណើរលេចមកនៃសិរីល្អរបស់ព្រះដ៏ជាធំ នឹងព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្ដីទទឹងច្បាប់ ហើយនឹងសំអាតមនុស្ស១ពួក ទុកដាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ» (ទីតុស ២:១១-១៤)។

សូមសរសើរតម្កើងដល់ព្រះជាម្ចាស់ ចំពោះព្រះគុណដ៏អស្ចារ្យនេះ!

៧

# មែនហើយ ប៉ុន្តែ...តើខ្ញុំអាចដឹងជាក់បានដោយរបៀបណា?

ខណៈពេលលោកអ្នកអានអំពីការទាំងនេះ តើលោកអ្នកប្រាកដថា លោកអ្នកមានជីវិតអស់កល្បជានិច្ចដែរឬទេ? ឬមួយក៏លោកអ្នកកំពុងតែស្វែងរកភាពប្រាកដប្រជានៅក្នុងសេចក្តីសង្គ្រោះរបស់លោកអ្នក?

ជាការដ៏គួរឲ្យសោកស្តាយណាស់ មានគ្រីស្ទបរិស័ទជាច្រើននាក់មិនមានភាពប្រាកដប្រជាថាពួកគេមានជីវិតអស់កល្បជានិច្ចទេ។ ប៉ុន្តែសាវ័ក យ៉ូហាន បានបញ្ជាក់យ៉ាងច្បាស់ថា៖ «ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ» (១យ៉ូហាន ៥:១៣)។

យើងមិនអាចដឹងច្បាស់ថាយើងមានជីវិតអស់កល្បជានិច្ចបាននោះទេ ប្រសិនបើវាពឹងផ្អែកលើរបៀបដែល

យើងប្រព្រឹត្ត ឬអាស្រ័យថាតើយើងមានអារម្មណ៍ស្មោះត្រង់ប៉ុណ្ណានោះ។ ប៉ុន្តែ ព្រះគម្ពីរសញ្ញាថ្មីទាំងមូលបានសន្មតថា អ្នកជឿអាចប្រាកដអំពីរឿងនេះបាន។ សាវ័កប៉ុល សរសេរទៅកាន់អ្នកជឿនៅទីក្រុងភីលីពថា «ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង» (ភីលីព ៤:៤)។ ប៉ុន្តែ តើខ្ញុំអាចអរសប្បាយបានដោយរបៀបណា ប្រសិនបើខ្ញុំមិនប្រាកដក្នុងព្រះអម្ចាស់ ហើយក៏មិនប្រាកដអំពីជំហររបស់ខ្ញុំនៅចំពោះទ្រង់ផងនោះ? ព្រះយេស៊ូវមានបន្ទូលថា៖ «ត្រូវឲ្យរីករាយ ដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុកនៅស្ថានសួគ៌វិញ» (លូកា ១០:២០)។ ជាថ្មីម្តងទៀត តើខ្ញុំអាចអរសប្បាយដោយរបៀបណា ប្រសិនបើខ្ញុំមិនដឹងថា ឈ្មោះរបស់ខ្ញុំត្រូវបានកត់ទុកនៅទីនោះផងឬក៏អត់នោះ? តើសេចក្តីសង្ឃឹមអំពីការរស់ឡើងវិញនៅក្នុងព្រះគម្ពីរសញ្ញាថ្មីកម្សាន្តចិត្តខ្ញុំយ៉ាងដូចម្តេចបាន ប្រសិនបើខ្ញុំមិនដឹងច្បាស់ថា ខ្ញុំនឹងត្រូវបានប្រោសឲ្យរស់ឡើងវិញជាមួយព្រះគ្រីស្ទដែរ ឬក៏អត់ផងនោះ?

ការរាប់ជាសុចរិតដោយសារជំនឿតែមួយមុខគឺជាគន្លឹះដែលបើកទ្វារចូលទៅកាន់ការកម្សាន្តចិត្ត និងអំណរ។

ប្រសិនបើជំហរដ៏ត្រឹមត្រូវរបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់អាស្រ័យលើខ្ញុំ និងអ្វីដែលខ្ញុំធ្វើ នោះខ្ញុំនឹងព្រួយបារម្ភ ហើយមានអារម្មណ៍មិនសប្បាយចិត្តជាមិនខាន។ តើព្រះជាម្ចាស់ទាស់ប្រឆាំងនឹងខ្ញុំឬ? តើខ្ញុំត្រូវបានកាត់ផ្តាច់ចេញពីទ្រង់ឬ?

ការថប់បារម្ភបែបនេះនឹងពិតជាអាចបំផ្លាញជីវិតនៃការអធិស្ឋានរបស់លោកអ្នកបានមែន។ វាអាចដកចេញនូវអំណរទាំងប៉ុន្មាននៅក្នុងទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងព្រះជាម្ចាស់។ ការមើលឃើញអំពើបាបរបស់ខ្លួន ខណៈពេលដែលអ្នកឯទៀតហាក់ដូចជាល្អឥតខ្ចោះ គឺអាចនាំលោកអ្នកឲ្យចង់ដកខ្លួនចេញពីក្រុមជំនុំ ហើយបិទព្រះគម្ពីរចោល។

ប្រសិនបើលោកអ្នកដឹងអំពីអារម្មណ៍នោះថាមានលក្ខណៈបែបណា នេះជាដំបូន្មានរបស់លោក ម៉ាធិន លូសើរ ទៅកាន់មិត្តម្នាក់របស់គាត់ដែលបានតយុទ្ធជាមួយនឹងការមានអារម្មណ៍ប្រាកដប្រជា៖

> «នៅពេលដែលអារក្សចោទប្រកាន់យើងអំពីអំពើបាបរបស់យើង ហើយនិយាយថាយើងសមនឹងទទួលសេចក្តីស្លាប់ និងស្ថាននរក នោះយើងគួរតែនិយាយដូចនេះថា៖ “ខ្ញុំទទួលស្គាល់ថា ខ្ញុំសមនឹងទទួលសេចក្តីស្លាប់ និងស្ថាននរកមែន។ ដូច្នេះ តើយ៉ាង

> ម៉េច? តើនេះមានន័យថា ខ្ញុំនឹងត្រូវទទួលទណ្ឌកម្មជារៀងរហូតមែនឬ? ទេ មិនដូច្នោះទេ។ ខ្ញុំស្គាល់បុគ្គលម្នាក់ដែលបានរងទុក្ខ ហើយធ្វើឲ្យអ្វីៗបានត្រឡប់ជាត្រឹមត្រូវសម្រាប់ខ្ញុំវិញ។ ព្រះនាមរបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ។ កន្លែងណាដែលព្រះអង្គគង់នៅ នោះខ្ញុំក៏នឹងនៅទីនោះដែរ"»។

នេះជាមូលហេតុដែលការរាប់ជាសុចរិតគឺជាសេចក្តីពិតដ៏កម្សាន្តចិត្តមួយដែលយើងត្រូវកាន់ខ្ជាប់។ នេះមានន័យថា ទោះបីជាយើងដឹងអំពីភាពខ្មៅងងឹត និងភាពកខ្វក់របស់យើងក៏ដោយ ក៏យើងនៅតែអាចមករកព្រះដ៏បរិសុទ្ធដោយចិត្តស្មោះសអំពីការបរាជ័យរបស់យើង និងដោយភាពក្លាហានដ៏ពេញលេញដោយសារតែព្រះគ្រីស្ទ។ ការរាប់ជាសុចរិតដោយសារជំនឿតែមួយមុខផ្តល់ឲ្យយើងនូវភាពស្មោះត្រង់ និងភាពក្លាហាននៅចំពោះព្រះជាម្ចាស់។

ដោយសារព្រះបានប្រកាសថា អ្នកជឿដែលនៅតែប្រព្រឹត្តបាប និងជំពប់ដួលជាមនុស្សសុចរិតដោយឥតគិតថ្លៃនៅក្នុងព្រះគ្រីស្ទ នោះយើងមិនដាក់ទំនុកចិត្តលើខ្លួនឯងបានទេ។ យើងអាចដាក់ទំនុកចិត្តទាំងអស់របស់យើងលើព្រះគ្រីស្ទ និងសេចក្តីសុចរិតរបស់ទ្រង់ដែលនោះគ្រប់គ្រាន់ហើយ។ គ្មានអំពើបាបណាធំជាង

ព្រះលោហិតនៃកូនចៀមនេះទេ ហើយព្រះអង្គបានគ្រប បាំងអ្នកជឿនៅក្នុងទ្រង់។ យើងមិនចាំបាច់ខ្លាចថ្ងៃនៃការ ជំនុំជម្រះនោះទេ ពីព្រោះថ្ងៃនោះជាថ្ងៃរបស់ព្រះយេស៊ូវដ៏ ជាមិត្តសម្លាញ់របស់យើង ដែលទ្រង់បានប្រទានសេចក្តី សុចរិតរបស់ទ្រង់មកយើង។

ការកម្សាន្តចិត្តដែលបានផ្តល់ឲ្យដល់អស់អ្នកដែល យល់អំពីដំណឹងល្អនេះមានការបង្ហាញឲ្យឃើញនៅ ក្នុងសំណេរដ៏មានឥទ្ធិពលនៃសៀវភៅ «គោលលទ្ធិ គ្រីស្ទានហៃដែលប៊ឺក» (Heidelberg Catechism សំណួរចម្លើយអំពីគោលជំនឿគ្រីស្ទបរិស័ទ)៖

*សំណួរទី៥២៖* តើអ្នកទទួលបាននូវសេចក្តីកម្សាន្ត ចិត្តយ៉ាងដូចម្តេចខ្លះ ដែលព្រះគ្រីស្ទនឹងយាងមក ដើម្បី ជំនុំជម្រះទាំងមនុស្សរស់ និងមនុស្សស្លាប់?

*ចម្លើយទី៥២៖* នៅក្នុងគ្រប់ទាំងសេចក្តីទុក្ខព្រួយ និង ការបៀតបៀនទាំងអស់របស់ខ្ញុំ ខ្ញុំនឹងងើបមុខឡើងរង ចាំព្រះមួយអង្គនោះឯងដែលបានថ្វាយអង្គទ្រង់ ដើម្បី ទទួលនូវសេចក្តីជំនុំជម្រះរបស់ព្រះជាម្ចាស់ជំនួសខ្ញុំ ព្រមទាំងបានដកអស់ទាំងបណ្តាសាចេញពីខ្ញុំ។

លែងមានបណ្តាសាទៀតហើយ។ យើងអាចរីករាយ នឹងការធានាជាមួយនឹងភាពប្រាកដប្រជាបាន។

ភាពឥតលោក់ពុតរបស់គ្រូអធិប្បាយម្នាក់ បានបណ្ដាលឲ្យលោកស្រី ហ្វ្រានស៊ីស (Frances) ស្ដាប់ និងផ្ដោតអារម្មណ៍។ ក្នុងរយៈពេលប៉ុន្មានខែកន្លងមកនេះ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឲ្យនាងយល់ច្បាស់អំពីសេចក្ដីពិតនៃព្រះគម្ពីរ។ មិនយូរប៉ុន្មាន បន្ទាប់ពីម៉ោង ១២:០០ យប់ក្នុងឆ្នាំ១៩៥៣ ស្ដ្រីវ័យក្មេងរូបនេះបានជួបជាមួយព្រះគ្រីស្ទដ៏មានព្រះជន្មរស់។ នៅពេលដែលកម្មពិធីថ្វាយបង្គំបានបញ្ចប់ នោះគ្រូគង្វាលបានអញ្ជើញអ្នកដែលចង់ថាតាមការអធិស្ឋាននៃការប្រែចិត្ត និងការអធិស្ឋានពីការដាក់ជំនឿលើព្រះគ្រីស្ទ ឲ្យនៅចាំសិន ដើម្បីស្ដាប់បន្ថែមទៀតអំពីជីវិតជាគ្រីស្ទបរិស័ទ...

ដោយការពណ៌នាអំពីយប់នោះជាងហុកសិបឆ្នាំក្រោយមកលោកស្រី ហ្វ្រានស៊ីស បាននិយាយថា «ព្រះវត្តមានរបស់ព្រះគ្រីស្ទគឺច្បាស់មែនទែន ហើយក៏ប៉ះពាល់ចិត្តខ្ញុំជាខ្លាំង។ ខ្ញុំបានដើរត្រឡប់ទៅបន្ទប់របស់ខ្ញុំវិញដោយមានអារម្មណ៍ថា ព្រះវត្តមានរបស់ទ្រង់គឺមានពិតប្រាកដមែន»។

លោកស្រី Julia Cameron
*John Stott's Right Hand:*
*The Untold Story of Frances Whitehead*

## ៨

# «ហាលេលូយ៉ា! ព្រះអង្គសង្គ្រោះអ្វីក៏អស្ចារ្យយ៉ាងនេះ!»

«យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន» (១យ៉ូហាន ៤:១៩)។

សេចក្តីពិតដ៏សាមញ្ញនោះគឺថា លោកអ្នកនឹងមិនស្រឡាញ់ព្រះជាម្ចាស់នោះទេ លុះត្រាតែលោកអ្នកដឹងថា ព្រះអង្គស្រឡាញ់លោកអ្នកជាមុនសិន។ លោកអ្នកនឹងមិនអាចស្រឡាញ់ទ្រង់បានទេ លុះត្រាតែលោកអ្នកប្រាកដថា លោកអ្នកអាចរីករាយនឹងការនៅជាមួយនឹងទ្រង់សិន។ ការរាប់ជាសុចរិតដោយសារជំនឿតែមួយមុខ ត្រូវតែជាមូលដ្ឋានគ្រឹះនៃការរស់នៅរបស់គ្រីស្ទបរិស័ទដែលមានសុខភាពល្អ។ បើគ្មានការរាប់ជាសុចរិតនេះទេ នោះលោកអ្នកនឹងមិនអាចរស់នៅក្នុងជីវិតជាគ្រីស្ទបរិស័ទបានពេញលេញឡើយ។ លោក

អ្នកនឹងមិនមានអំណរ និងភាពស្មោះត្រង់ដ៏ពិតប្រាកដនៅចំពោះព្រះជាម្ចាស់បានទេ។

ដួងចិត្តរបស់លោកអ្នកនឹងសម្រាកនៅក្នុងទ្រង់ នៅពេលដែលលោកអ្នកមើលឃើញសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់ និងរបៀបដែលព្រះអង្គប្រព្រឹត្តចំពោះលោកអ្នកដោយសប្បុរស និងដោយមិនអាស្រ័យលើការប្រព្រឹត្តរបស់លោកអ្នកនោះទេ។ ការរាប់ជាសុចរិតចាប់ផ្ដើមនាំយើងចូលក្នុងផ្លូវនៃព្រះគុណដែលនាំយើងចេញពីការអត់ទោសនៅក្នុងដំណឹងល្អទៅកាន់ព្រះដែលអត់ទោសយើង និងទៅកាន់ព្រះដ៏ជាមេផ្ដើមនៃដំណឹងល្អផ្ទាល់តែម្ដង។ ការរាប់ជាសុចរិតចង្អុលបង្ហាញយើងទៅរកព្រះជាម្ចាស់។ ខណៈដែលយើងអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះព្រះគុណរបស់ទ្រង់មកលើយើង នោះយើងក៏ចាប់ផ្ដើមសរសើរតម្កើងទ្រង់ ហើយរកឃើញអំណរក្នុងសេចក្ដីពិតដែលថា ព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា សប្បុរស និងប្រកបដោយព្រះគុណ។

បើគ្មានការយល់ដឹងអំពីការរាប់ជាសុចរិតទេ នោះយើងប្រហែលជាគិតថា ព្រះជាម្ចាស់គ្រាន់តែមានព្រះហឫទ័យម៉ឺងម៉ាត់ និងតឹងរ៉ឹង ដោយទទួលស្គាល់តែអស់អ្នកដែលបានដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេហើយតែប៉ុណ្ណោះ។ ព្រះប្រភេទនេះអាចមានសិទ្ធិធ្វើ

ជាព្រះដ៏តឹងរ៉ឹងបាន ប៉ុន្តែយើងនឹងមិនអាចស្រឡាញ់ទ្រង់ឲ្យអស់ពីចិត្តរបស់យើងបាននោះទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្ដីពិតនេះបង្ហាញយើងអំពីព្រះដែលស្រឡាញ់មនុស្សដែលបរាជ័យក្នុងការស្រឡាញ់ជាមុនដែរ។ ដូចដែលលោក ម៉ធិន លូសើរ បានសរសេរថា៖

> «សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មិនស្វែងរកអ្នកដែលស័ក្តិសមហើយនោះទេ ប៉ុន្តែសេចក្ដីស្រឡាញ់របស់ទ្រង់ធ្វើឲ្យយើងស័ក្តិសមវិញ។ សេចក្ដីស្រឡាញ់របស់ព្រះស្រឡាញ់មនុស្សមានបាប មនុស្សអាក្រក់ មនុស្សល្ងង់ខ្លៅ និងមនុស្សទន់ខ្សោយ ដើម្បីធ្វើឲ្យពួកគេបានសុចរិត ល្អ មានប្រាជ្ញា និងរឹងមាំវិញ។ ជាជាងស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន សេចក្ដីស្រឡាញ់របស់ព្រះចែកចាយ និងផ្ដល់ប្រយោជន៍ដល់អ្នកឯទៀតវិញ។ ដូច្នេះ មនុស្សមានបាបមានភាពទាក់ទាញ ដោយព្រោះព្រះជាម្ចាស់បានស្រឡាញ់ពួកគេ...ពួកគេមិនបានទទួលសេចក្ដីស្រឡាញ់ ដោយព្រោះពួកគេមានភាពទាក់ទាញនោះទេ»។

លោក ម៉ធិន លូសើរ ធ្លាប់បានលើកឡើងថា លោកបានស្អប់ព្រះដែលគាត់បានគិតថាជាព្រះដែលគ្មានព្រះគុណ។ ប៉ុន្តែ បន្ទាប់មកលោកបានឃើញព្រះដែលមានព្រះហឫទ័យសប្បុរសយ៉ាងខ្លាំង គឺលោកមិនអាចធ្វើអ្វី

## បានទៀតក្រៅពីក្រាបចុះដោយភាពអស្ចារ្យដ៏រីករាយនៅចំពោះទ្រង់។

ឱមនុស្សមានបាប ជនក្រីក្រ និងជនខ្វះខាតទាំងឡាយអើយ សូមចូលមកចុះ។
អស់អ្នកដែលខ្សោយនិងរងទុក្ខ មានជម្ងឺនិងឈឺចាប់ក៏ដោយ។
ព្រះយេស៊ូវបានត្រៀមជាស្រេច ដើម្បីនឹងសង្គ្រោះអ្នករាល់គ្នាហើយ។
ព្រះអង្គពោរពេញដោយព្រះហឫទ័យអាណិតអាសូរ សេចក្ដីស្រឡាញ់ និងព្រះចេស្ដា។

ចូរមកចុះ អស់អ្នកដែលស្រេកអើយ ចូរមកហើយទទួលបាននូវការស្វាគមន៍ចុះ។
ចូរអបអរសាទរចំពោះសេចក្ដីសប្បុរសដ៏ឥតគិតថ្លៃរបស់ព្រះជាម្ចាស់
ដ្បិតជំនឿពិត និងការប្រែចិត្តពិត
គឺជាព្រះគុណដែលនាំអ្នករាល់គ្នាមកជិត។

កុំឲ្យមនសិការរបស់អ្នករាល់គ្នាធ្វើឲ្យអ្នករាល់គ្នាមានការសង្ស័យ
ឬចង់បានអារម្មណ៍ថា ខ្លួនល្អគ្រប់គ្រាន់នោះឡើយ។
អ្វីដែលព្រះអង្គតម្រូវឲ្យមានគឺឲ្យលោកអ្នកមានអារម្មណ៍ថា

អ្នករាល់គ្នាត្រូវការទ្រង់ប៉ុណ្ណោះ។
ចូរមកចុះ អស់អ្នកនឿយព្រួយ និងមានបន្ទុកធ្ងន់
ទាំងអ្នកដែលវង្វេង និងខ្ទេចខ្ទាំដោយសារបាបដែរ។
បើអ្នករាល់គ្នារង់ចាំរហូតដល់អ្នករាល់គ្នាបានប្រសើរជាងនេះ
នោះអ្នករាល់គ្នានឹងមិនដែលចូលមកនោះទេ។

ខ្ញុំនឹងក្រោកឡើង ហើយទៅរកព្រះយេស៊ូវ!
ព្រះអង្គនឹងសង្គ្រោះខ្ញុំពីអំពើបាបរបស់ខ្ញុំ។
ដោយសារតែតម្លៃដ៏អស្ចារ្យរបស់ទ្រង់
នោះមានអំណរ និងជីវិតនៅក្នុងទ្រង់។

– លោក យ៉ូសែប ហាត (Joseph Hart), ១៧៥៩

# ឯកសារយោង

"១៧១. លោក Thomas Bilney." ក្នុងការនិពន្ធរបស់លោក John Foxe, *The Acts and Monuments of the Church*. បកប្រែ និងកែសម្រួលដោយលោក Josiah Pratt និងលោក John Stoughton. London: The Religious Tract Society, ឆ្នាំ ១៨៧៧។

លោក Philip C. Bliss. "'Man of Sorrows,' What a Name," ឆ្នាំ ១៨៧៥។

លោក John Bunyan, *The Pilgrim's Progress*. Auburn: Derby and Miller; Buffalo: Geo. H. Derby & Co., ឆ្នាំ ១៨៥៣។

______. *Grace Abounding to the Chief of Sinners*. ក្នុង *The Works of* លោក *John Bunyan*. វគ្គ១, *Experimental, Doctrinal, and Practical*. កែសម្រួលដោយលោក George Offor. Edinburgh: Banner of Truth, ឆ្នាំ១៩៩១។

លោក John Calvin, *Institutes of Christian Religion*. កែសម្រួលដោយលោក John T. MacNeill. បកប្រែដោយលោក Ford Lewis Battles. Philadelphia: Westminster Press, ឆ្នាំ ១៩៦០។

លោក Martin Luther, "Preface to the Complete Edition of Luther's Latin Writings." ក្នុង *Luther's Works*. វគ្គ៣៤, *Career of the Reformer IV*. កែសម្រួលដោយលោក Lewis William Spitz និងលោក Helmut T. Lehmann. Philadelphia: Fortress; St. Louis, MO: Concordia, ឆ្នាំ ១៩៦០។

______. *The Freedom of the Christian; Heidelberg Disputation; Two Kinds of Righteousness*. In *Luther's Works*. វគ្គ៣១, *Career of the Reformer I*. កែសម្រួលដោយលោក Lewis William Spitz និងលោក Helmut T. Lehmann. Philadelphia: Fortress; St. Louis, MO: Concordia, ឆ្នាំ ១៩៦០។

______. "Letter to Jerome Weller." In *Luther: Letters of Spiritual Counsel*. បកប្រែ និងកែសម្រួលដោយលោក Theodore G. Tappert.

Philadelphia: Westminster Press, ឆ្នាំ ១៩៦៦ ២០០៦។

លោក Richard Sibbes, *The Complete Works of Richard Sibbes*. វគ្គ២។ កែសម្រួលដោយលោក Alexander B. Grosart. Edinburgh: Nichol, ឆ្នាំ ១៨៦២។

លោក William Tyndale, *A Pathway into the Holy Scripture*. In *The Works of the English Reformers: William Tyndale and John Frith*. វគ្គ២។ កែសម្រួលដោយលោក Thomas Russell. London: Palmer, ឆ្នាំ ១៨៣១។

លោក Charles Wesley, "And Can It Be, That I Should Gain?" ឆ្នាំ ១៧៣៨។

# លិបិក្រមតាមព្រះគម្ពីរ


## សញ្ញាចាស់

### លោកុប្បត្តិ

៣:៧ .............. ៣៣
៣:២១ .............. ៣៣
១៥:៦ .............. ២៣, ៥១
២៧:២៧ .............. ៣២

### ទំនុកតម្កើង

៣២:១-២ .............. ២៦, ២៦

### អេសាយ

៦១:១០-៦២ .............. ៣៩

### យេរេមា

២៣:៦ .............. ៣០

## សញ្ញាថ្មី

### លូកា

១០:២០ .............. ៦២

### យ៉ូហាន

៤:១៩ .............. ៦៧
៥:១៣ .............. ៦១
១៤:១៩ .............. ៣៦

### រ៉ូម

១:១៧ .............. ១៧
៣:១០ .............. ២១
៣:២៣-២៤ .............. ២២
៤:១-៨ .............. ២៣
៤:៧-៨ .............. ២៦
៤:២៥ .............. ៣០
៦:១ .............. ៥៥
៦:៣ .............. ២៩

**១កូរិនថូស**

១:៣០ . . . . . . . . . . . . . ៣០, ៣៥

**២កូរិនថូស**

៥:២១ . . . . . . . . . . . . . ៣១

**ភីលីព**

១:២៣ . . . . . . . . . . . . . ៥៧
៣:៨-៩ . . . . . . . . . . . . ៣១
៤:៤ . . . . . . . . . . . . . . ៦២

**កូឡូស**

២:១២ . . . . . . . . . . . . . ២៩

**១ធីម៉ូថេ**

៣:១៦ . . . . . . . . . . . . . ៣០

**ទីតុស**

២:១១-១៤ . . . . . . . . . ៥៨

**ហេព្រើរ**

១៣:៨ . . . . . . . . . . . . . ៣៥

**យ៉ាកុប**

២:១៤-២៦ . . . . . . . . ៥១
២:១៤-២៥ . . . . . . . . ៤៩

**១យ៉ូហាន**

៤:១៩ . . . . . . . . . . . . . ៦៧
៥:១៣ . . . . . . . . . . . . . ៦១

**វិវរណៈ**

១៩:៦-៨ . . . . . . . . . . . ៣៩

សៀវភៅផ្សេងៗទៀតនិពន្ធ
ដោយលោក
Michael Reeves

*Authentic Ministry: Serving from the Heart*

*What Does It Mean to Fear the Lord?*

*What Fuels the Mission of the Church?*

*Enjoy Your Prayer Life: Exercise Your Faith*

សៀវភៅផ្សេងៗទៀតនិពន្ធ
ដោយក្រុម
Union Publishing

*Authentic Ministry:*
*Serving from the Heart*
by Michael Reeves

*Iron Sharpens Iron:*
*Friendship and the Grace of God*
by Michael A.G. Haykin

# អំពីក្រុម Union

**យើងជំរុញឲ្យមានការកែទម្រង់ (Reformation) នៅក្នុងក្រុមជំនុំ និងនៅក្នុងជីវិតរស់នៅជាប្រចាំថ្ងៃ។**

ក្រុមបោះពុម្ពផ្សាយ Union Publishing វិនិយោគលើអ្នកដឹកនាំជំនាន់ក្រោយៗ ដោយផ្ដល់ជូននូវសេចក្ដីបង្រៀនខាងឯទេវវិទ្យា ដែលធ្វើឲ្យពួកគេស្រេកឃ្លាន និងចង់ស្គាល់ព្រះជាម្ចាស់ឲ្យកាន់តែស៊ីជម្រៅជាងមុន។ ចាប់តាំងពីសៀវភៅ រហូតដល់ធនធានអនឡាញដែលយើងផ្ដល់ដោយឥតគិតថ្លៃ គឺយើងប្ដេជ្ញាចិត្តផលិតធនធានដ៏ល្អៗ ដែលនឹងជួយកម្សាន្តចិត្ត ផ្លាស់ប្ដូរជីវិត និងបណ្ដុះបណ្ដាលអ្នកជឿ ព្រមទាំងក្រុមជំនុំរបស់ពួកគាត់ឲ្យកាន់តែរីកចម្រើនឡើង។

យើងចង់ឲ្យមនុស្សនៅគ្រប់ទីកន្លែងបានស្គាល់ ស្រឡាញ់ និងមានអំណរក្នុងព្រះជាម្ចាស់ ដោយលើកតម្កើងសិរីល្អរបស់ទ្រង់នៅក្នុងគ្រប់កិច្ចការទាំងអស់ដែលពួកគាត់ធ្វើ។ ដោយហេតុផលនេះ នោះយើងក៏

បានប្រមូលផ្តុំនូវអត្ថបទ ផតខាស (podcasts) ជំពូកពីសៀវភៅផ្សេងៗ និងវីដេអូដែលផ្តល់ដោយឥតគិតថ្លៃរាប់រយវីដេអូ ដើម្បីដាក់បញ្ចូលទៅក្នុងបណ្តុំអនឡាញដោយឥតគិតថ្លៃដល់បងប្អូនរួមជំនឿ។ យើងក៏ផលិតនូវធនធានថ្មីៗជាបន្តបន្ទាប់ ទាំងជាទម្រង់អត្ថបទ សំឡេង និងវីដេអូ ដើម្បីជួយឲ្យជីវិតរបស់លោកអ្នកមានភាពរស់រវើកឲ្យកាន់តែពេញខ្នាតជាងមុន នៅក្នុងសេចក្តីពិត សេចក្តីសប្បុរស និងភាពស្រស់ស្អាតរបស់ព្រះយេស៊ូវ។

*ប្រសិនបើលោកអ្នកស្រេកឃ្លាន និងចង់បានធនធានបែបកែទម្រង់ ដែលនឹងជួយឲ្យលោកអ្នកមានសេចក្តីអំណរនៅក្នុងព្រះជាម្ចាស់ និងលូតលាស់នៅក្នុងព្រះគ្រីស្ទ យើងសូមអញ្ជើញលោកអ្នកឲ្យចូលទៅកាន់គេហទំព័ររបស់យើងតាមរយៈ unionpublishing.org.*